# ជំងឺកាមរោគ

កាមរោគ គឺជាជំងឺឆ្លងដែលបន្តពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្នុងពេលរួមភេទ។

ការរួមភេទជាច្រើនរបៀប អាចចម្លងជំងឺកាមរោគ។ វាអាចជាការរួមភេទតាមលិង្គទៅទ្វារមាស តាមលិង្គទៅរន្ធគូថ ឬតាមមាត់ (មាត់ទៅលិង្គ មាត់ទៅទ្វារមាស)។ ជួនកាលជំងឺកាមរោគក៏អាចឆ្លងគ្រាន់តែការត្រដុសលិង្គ ឬទ្វារមាសដែលមានមេរោគ ទៅនឹងប្រដាប់ភេទរបស់មនុស្សម្នាក់ទៀត។

រោគសញ្ញាបង្កឡើងដោយជំងឺកាមរោគ មានដូចជា ឈឺចាប់ក្នុងពេលរួមភេទ, ធ្លាក់សឬខ្ទុះខុសធម្មតាពីទ្វារមាស លិង្គ ឬរន្ធគូថ, ដុំ ដំបៅ ឬពងបែកនៅលើប្រដាប់ភេទ។




វាពិបាកណាស់ក្នុងការនិយាយអំពីការរួមភេទ! ការជួយឲ្យប្រជាជនការពារខ្លួន, ទទួលការធ្វើតេស្ត, និងស្វែងរកការព្យាបាល នឹងបញ្ឈប់ការឆ្លងរាលដាលជំងឺកាមរោគ។

**ជាញឹកញាប់ មនុស្សម្នាក់មានជំងឺកាមរោគ តែគ្មានរោគសញ្ញាអ្វីទាំងអស់។** បើទោះជាគ្មានរោគសញ្ញាអ្វីក៏ដោយ ជំងឺកាមរោគនៅតែអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបាន។ ការធ្វើតេស្ត គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីរកឱ្យឃើញថាមនុស្សម្នាក់មានជំងឺកាមរោគដែរឬទេ រួចស្វែងរកការព្យាបាលដ៏ត្រឹមត្រូវដើម្បីឲ្យជាសះស្បើយ។ នៅកន្លែងដែលមិនអាចរកការធ្វើតេស្តបាន វានៅតែជាការសំខាន់ដែលត្រូវព្យាបាលជំងឺភ្លាមៗ។ សូមជួយមនុស្សដែលអ្នកបានរួមភេទជាមួយ ឲ្យទទួលបានការធ្វើតេស្តនិងព្យាបាលផងដែរ។ ប្រសិនបើអ្នកទាំងពីរមិនបានទទួលការព្យាបាលទេ នោះអ្នកនឹងឆ្លងរោគម្តងទៀត ហើយឆ្លងទៅមនុស្សផ្សេងទៀត។

ជំងឺកាមរោគភាគច្រើនត្រូវបានព្យាបាលជាសះស្បើយ បន្ទាប់ពីការប្រើថ្នាំអង់ទីប៊ីយោទិក។ ជំងឺកាមរោគផ្សេងទៀតមិនបាត់ទៅវិញទេ ប៉ុន្តែអាចគ្រប់គ្រងបានដោយប្រើថ្នាំពេទ្យ។ ក៏មានការព្យាបាលដើម្បីកាត់បន្ថយភាពឈឺចាប់ផងដែរ និងជួយសម្រាលភាពលំបាកនៅពេលដែលថ្នាំនេះចាប់ផ្តើមមានប្រសិទ្ធភាព (សូមមើលពី របៀបធ្វើឲ្យមានអារម្មណ៍ធូរស្រាល ក្នុងពេលដែលអ្នកជាសះពីជំងឺកាមរោគ, ទំព័រ 19)។

ការមិនរួមភេទ ឬការប្រាកដថាដៃគូផ្លូវភេទរបស់អ្នក មិនមានជំងឺកាមរោគ គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីបង្ការជំងឺកាមរោគ។ ដោយសារតែលក្ខខណ្ឌបែបនេះ វាមិនអាចកើតឡើងជាដរាបនោះទេ ដូច្នេះ ការបង្ការជំងឺពីការរួមភេទ ដោយប្រើស្រោមអនាម័យគ្រប់ពេល គឺជាមធ្យោបាយមួយទៀតដើម្បីកាត់បន្ថយឱកាសឆ្លងជំងឺកាមរោគ (ទំព័រ 21)។ បុគ្គលិកសុខាភិបាលអាចដើរតួនាទីយ៉ាងសំខាន់ តាមរយៈការប្រាស្រ័យទាក់ទងជាមួយអ្នកដែលមានជំងឺកាមរោគ ដោយមិនរើសអើង និងប្រកបដោយភាពថ្លៃថ្នូរ (មើលទំព័រ 26)។

# ហេតុអ្វីជំងឺកាមរោគគឺជាបញ្ហាធ្ងន់ធ្ងរ



ដោយសារតែការរួមភេទគឺជារឿងដែលកើតឡើងជាទូទៅ ដូច្នេះជំងឺកាមរោគក៏កើតឡើងជាញឹកញាប់ផងដែរ។ នៅពេលដែលជំងឺកាមរោគមិនត្រូវបានព្យាបាលទេ វាអាចបង្កគ្រោះថ្នាក់ដល់ស្ត្រី បុរស និងកុមារ។ ជំងឺកាមរោគអាចបណ្តាលឱ្យ៖

- មានភាពអារទាំងលើបុរស និងស្ត្រី។
- ទារកកើតមិនគ្រប់ខែ កើតមកតូចពេក ងងឹតភ្នែក ឈឺ ឬស្លាប់។
- ស្លាប់ដោយសារការបង្ករោគធ្ងន់ធ្ងរ។
- ឈឺចាប់យូរអង្វែង។
- មហារីកមាត់ស្បូន ឬបំពង់ក ឬរន្ធគូថ។
- ហានិភ័យកើនឡើងចំពោះការឆ្លងជំងឺកាមរោគផ្សេងទៀត រួមទាំងមេរោគអេដស៍។

# របៀបដែលជំងឺកាមរោគ ឆ្លងទៅដៃគូតាមរយៈការរួមភេទ

ទាំងបុរសនិងស្ត្រី សុទ្ធតែអាចឆ្លងជំងឺកាមរោគ។ ប៉ុន្តែអ្នកដែលទទួល, ដូចជាត្រូវបានលិង្គស៊កចូលក្នុងទ្វារមាស ឬរន្ធគូថ, មានគ្រោះថ្នាក់ជាង។ បើគ្មានស្រោមអនាម័យទេ ទឹកកាមដែលប្រហែលជាផ្ទុកមេរោគស្ថិតនៅក្នុងទ្វារមាស រន្ធគូថ ឬមាត់។ ការស៊កលិង្គចូលអាចត្រកួតនិងធ្វើឲ្យរលាត់ស្បែកនៅក្នុងទ្វារមាស ឬរន្ធគូថ ដែលបង្កើនឱកាសនៃការឆ្លងមេរោគចូលទៅក្នុងខ្លួន។ បែបនេះអាចកើតឡើង បើទោះជាអ្នកនោះមិនមានអារម្មណ៍ថាមានដំបៅនៅក្នុងទ្វារមាសឬរន្ធគូថក៏ដោយ។ ដំបៅ ឬរមាស់ នៅផ្នែកខាងក្រៅនៃប្រដាប់ភេទ ក៏អាចចម្លងជំងឺកាមរោគ រួមទាំងមេរោគអេដស៍ កាន់តែងាយស្រួលផងដែរ ។

# គួរធ្វើដូចម្តេចប្រសិនបើអ្នកប្រហែលជាមានជំងឺកាមរោគ

- ធ្វើតេស្ត ប្រសិនបើអាចស្វែងរកបាន
- ទទួលយកការព្យាបាលជាបន្ទាន់ ដោយមិនត្រូវចាំទាល់តែឈឺធ្ងន់នោះទេ
- ជួយដៃគូរបស់អ្នកឲ្យទទួលបានការព្យាបាលក្នុងពេលជាមួយគ្នា។ តាមវិធីនេះ អ្នកនឹងមិនឆ្លងមេរោគទៀតទេ ប្រសិនបើអ្នករួមភេទជាមួយគ្នា។



# តើខ្ញុំមានជំងឺកាមរោគដែរឬទេ?

រោគសញ្ញានៃជំងឺកាមរោគ មានដូចជា ធ្លាក់សបូហូរខ្ទុះ ឈឺចាប់ ដំបៅនៅប្រដាប់ភេទ។ ប៉ុន្តែជំងឺកាមរោគជាច្រើន មិនធ្វើឱ្យមានរោគសញ្ញាអ្វីទេ។ ទោះបីគ្មានរោគសញ្ញាក៏ដោយ ជំងឺកាមរោគអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្នុងអំឡុងពេលរួមភេទដែលមិនប្រើស្រោមអនាម័យ។ ការធ្វើតេស្ត៍សំណាកឈាម ទឹកនោម ឬការផ្តិតលើកន្លែងដែលមានរោគសញ្ញា ត្រូវបានគេប្រើដើម្បីសន្និដ្ឋានថាតើជំងឺកាមរោគមួយណាដែលមនុស្សម្នាក់មាន។ ការធ្វើតេស្ត៍ ក៏ជាផ្នែកមួយនៃការថែទាំសុខភាពជាប្រចាំផងដែរ ដើម្បីស្វែងរក និងព្យាបាលជំងឺកាមរោគដែលមិន មានរោគសញ្ញា។

## ការធ្វើតេស្ត៍សម្រាប់ជំងឺកាមរោគ

ដើម្បីធ្វើតេស្ត៍ជំងឺកាមរោគ បុគ្គលិកសុខាភិបាលយក សំណាកពីអ្នកជំងឺ ហើយអាចប្រើឧបករណ៍ធ្វើតេស្ត៍ ឬរកមើលមេរោគដោយប្រើមីក្រូទស្សន៍។ ប្រភេទនៃ តេស្ត៍ជំងឺកាមរោគ រួមមាន៖



ការធ្វើតេស្ត៍ឈាម អាចពិនិត្យរកជំងឺកាមរោគមួយចំនួន។

- ការផ្តិតដោយប្រើដុំសំឡីនៅជុំវិញប្រដាប់ភេទ ផ្តល់នូវសំណាកសម្រាប់ធ្វើតេស្ត៍ជំងឺប្រមេះទឹកថ្លា ជំងឺប្រមេះទឹកបាយ ពងបែកលើប្រដាប់ភេទ ដំបៅប្រដាប់ភេទ ឬ ជំងឺទ្រីកូម៉ូណាស់។ ការផ្តិតនៅខាងក្នុងមាត់ អាចធ្វើតេស្ត៍រកមេរោគអេដស៍។ ការផ្តិតបំពង់ក ឬរន្ធគូថ ជួនកាលជាការចាំបាច់សម្រាប់ធ្វើតេស្ត៍រកជំងឺកាមរោគពីការរួមភេទតាមមាត់ឬរន្ធគូថ។ ការផ្តិតនៅមាត់ស្បូន អាចធ្វើតេស្ត៍រកមេរោគ HPV ។
- ការធ្វើតេស្ត៍ទឹកនោម អាចរកឃើញជំងឺប្រមេះទឹកថ្លា និងជំងឺប្រមេះទឹកបាយ។
- ការធ្វើតេស្ត៍ឈាម អាចរកឃើញជំងឺស្វាយ ពងបែកលើប្រដាប់ភេទ ជំងឺរលាកថ្លើម និងមេរោគអេដស៍។

ការធ្វើតេស្ត៍រកជំងឺកាមរោគ គឺជាគំនិតដ៏ល្អសម្រាប់អ្នកដែលសកម្មខាងផ្លូវភេទ។ ធ្វើតេស្ត៍ញឹកញាប់យ៉ាងណា អាស្រ័យលើថាតើអ្នកមានដៃគូថ្មី, មានដៃគូច្រើនជាងម្នាក់, ឬមានមូលហេតុដែលគិតថាប្រហែលជាមានជំងឺកាមរោគ ដែរឬទេ។ ប្រសិនបើអ្នកមានផ្ទៃពោះ វាជារឿងធម្មតាទេដែលគួរធ្វើតេស្ត៍រកជំងឺកាមរោគ ព្រោះវាអាចបង្កគ្រោះថ្នាក់ដល់ទារក ឬគ្រោះថ្នាក់ដល់អ្នក។

ប្រសិនបើអ្នកមានជំងឺកាមរោគមួយ សូមធ្វើតេស្ត៍រកជំងឺកាមរោគញឹកញាប់ផ្សេងទៀតផងដែរ ព្រោះជំងឺ ២ឬច្រើនមុខ អាចឆ្លងក្នុងពេលតែមួយ។

# រោគសញ្ញាដែលអាចជាជំងឺកាមរោគ

| ឈឺចាប់ ឬធ្លាក់សខុសធម្មតាពីទ្វារមាស | | | |
|---|---|---|---|
| ? | តើមានការឈឺចាប់នៅផ្នែកក្រោមនៃពោះ ឬឈឺចាប់ក្នុងពេលរួមភេទដែរឬទេ? | ➡ | នេះអាចជា ជំងឺរលាកអាងត្រគាក (PID), មើលទំព័រ 11។ |
| ? | តើមានការឈឺចាប់ឬក្រហាយពេលនោមដែរឬទេ? | ➡ | នេះអាចជាជំងឺរលាកផ្លូវនោម ហើយមិនមែនជាជំងឺកាមរោគទេ (អានជំពូក ភាពលំបាកក្នុងការនោម, កំពុងសរសេរ)។ ឬមួយវាអាចជា ជំងឺទ្រីកូម៉ូណាស់, ជំងឺប្រមេះទឹកបាយ, ឬជំងឺប្រមេះទឹកថ្លា, មើលទំព័រ 9។ |
| ? | តើទឹកដែលធ្លាក់មានពណ៌សឬពណ៌ប្រផេះ និងមានក្លិនអាក្រក់ឬក្លិនដូចត្រីដែរឬទេ ជាពិសេសបន្ទាប់ពីរួមភេទ? | ➡ | នេះអាចជា ជំងឺរលាកទ្វារមាសដោយបាក់តេរី, មើលទំព័រ 6។ ឬម្យ៉ាងទៀតដែលមិនសូវឃើញញឹកញាប់គឺ ជំងឺទ្រីកូម៉ូណាស់, មើលទំព័រ 9។ |
| ? | តើទឹកដែលធ្លាក់មានពណ៌លឿងឬបៃតងមែនទេ? | ➡ | នេះអាចជា ជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា, មើលទំព័រ 9។ វាក៏អាចជាជំងឺទ្រីកូម៉ូណាស់ ផងដែរ, មើលទំព័រ 9។ |
| ? | តើទឹកដែលធ្លាក់មានពណ៌ស, មើលទៅដូចប្រហុក ឬទឹកដោះគោ, ហើយមានក្លិនដូចមេរោគផ្សិតឬនំប័ងដែរឬទេ? | ➡ | នេះអាចជា ការបង្ករោគដោយមេរោគផ្សិត ដែលមិនមែនជាជំងឺកាមរោគទេ, មើលទំព័រ 7។ |

| ឈឺចាប់ ឬហូរទឹកមិនធម្មតាពីលិង្គបុរស | | | |
|---|---|---|---|
| ? | តើមានឈឺចាប់ឬក្រហាយក្នុងពេលនោមដែរឬទេ? | ➡ | នេះអាចជា ជំងឺប្រមេះទឹកបាយ ឬ ជំងឺប្រមេះទឹកថ្លា, មើលទំព័រ 9។ ឬម្យ៉ាងទៀតដែលមិនសូវឃើញញឹកញាប់គឺ ជំងឺទ្រីកូម៉ូណាស់, មើលទំព័រ 9។ |
| ? | តើមានឈឺចាប់ឬឈឺហើមនៅក្នុងពងស្វាសដែរឬទេ? | ➡ | នេះអាចជា ជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា, មើលទំព័រ 9។ មូលហេតុផ្សេងៗទៀតក៏ត្រូវការការព្យាបាលដែរ ដូច្នេះត្រូវនិយាយជាមួយបុគ្គលិកសុខាភិបាល។ |
| ? | តើមានហូរទឹកចេញពីលិង្គស្រក់តក់ៗដែរឬទេ? | ➡ | នេះអាចជា ជំងឺប្រមេះទឹកបាយ, មើលទំព័រ 9។ |

| ដំបៅ និងសាច់ដុះនៅលើប្រដាប់ភេទ ឬនៅជិតរន្ធគូថ | | |
|---|---|---|
| ? តើមានដំបៅចំហដែលគ្មានការឈឺចាប់ ព្រមទាំងមានគែមផុសឡើងដែរឬទេ? | ➡ | នេះអាចជា ជំងឺស្វាយ, មើលទំព័រ 12។ |
| ? តើមានដំបៅឈឺចាប់មួយឬច្រើនដែលហើមនិងអាចហូរឈាមយ៉ាងងាយដែរឬទេ? | ➡ | នេះអាចជា ជំងឺដំបៅប្រដាប់ភេទ, មើលទំព័រ 12។ |
| ? តើមានពងបែកតូចៗដែលបែក ហើយកើតជាដំបៅចំហដែលឈឺចាប់ ដែរឬទេ? | ➡ | នេះអាចជា ជំងឺពងបែកនៅប្រដាប់ភេទ(herpes), មើលទំព័រ 14។ |

| រោគសញ្ញាផ្សេងទៀតចំពោះបុរសឬស្ត្រីនៅប្រដាប់ភេទឬរន្ធគូថ |
|---|
| ការរមាស់រន្ធគូថ ឬការឈឺចាប់ពេលបន្ទោរបង់លាមក ជួនកាលអាចជាសញ្ញានៃជំងឺកាមរោគ។ ម្យ៉ាងទៀត បើអ្នកសង្កេតឃើញការហូរសារធាតុរាវចេញពីរន្ធគូថ ឬវារអិលៗនៅពេលដែលអ្នកជូតគូថ នេះវាអាចជាសញ្ញានៃ ជំងឺប្រមេះទឹកបាយ ឬ ជំងឺប្រមេះទឹកថ្លា, មើលទំព័រ 9។ |
| ចូររកជំនួយពីគ្រូពេទ្យចំពោះរោគសញ្ញានៃជំងឺធ្ងន់ធ្ងរ ដែលរួមមានការហូរសារធាតុរាវពីទ្វារមាស លិង្គ ឬរន្ធគូថ ដែលវាមានឈាម ឬពណ៌ត្នោត។ |

## ការរមាស់ប្រដាប់ភេទ

ការរមាស់នៅជុំវិញរន្ធបើកនៃទ្វារមាស, នៅលើភ្លៅ ឬនៅកន្លែងដែលទឹកនោមចេញ អាចជា ការបង្ករោគដោយមេរោគផ្សិត (មើលទំព័រ 7) ឬចំពោះស្ត្រីវិញ ជាសញ្ញានៃ ជំងឺទ្រីកូម៉ូណាស់ (មើលទំព័រ 9)។

ប្រដាប់ភេទរមាស់ ក៏អាចជាចៃឬកមរមាស់នៅលើថ្ងាសនៃប្រដាប់ភេទផងដែរ ដែលជាសត្វតូចល្អិតជាខ្លាំងរស់នៅលើស្បែក។ វាត្រូវបានព្យាបាលដោយការលាបថ្នាំនៅលើស្បែក ដូចជាថ្នាំដែលមានជាតិ permethrin (មើលជំពូក បញ្ហាស្បែក, កំពុងសរសេរ) ។ បញ្ហាកមរមាស់អាចឆ្លងយ៉ាងងាយទៅសមាជិកគ្រួសារ។ វាកើតឡើងញឹកញាប់លើកុមារ ហើយប៉ះពាល់ដល់ផ្នែកជាច្រើននៃរាងកាយ។

បញ្ហារមាស់ក៏អាចបណ្ដាលមកពីសាប៊ូ ទឹកអប់ ឬសារធាតុគីមីដែលលាបលើឬក្នុងប្រដាប់ភេទផងដែរ។ ចូរលាងសម្អាតផ្នែកខាងក្រៅនៃប្រដាប់ភេទដោយទឹកធម្មតា ដើម្បីមើលថាតើបញ្ហារមាស់ បាត់ទៅវិញដែរឬទេ។

**សារធាតុរាវ(ធ្លាក់ស)ចេញពីទ្វារមាស**

ជាធម្មតា ស្ត្រីមានការធ្លាក់សខ្លះពីទ្វារមាស នៅចន្លោះរដូវរបស់គាត់។ នេះជាវិធីដែលទ្វារមាសធ្វើការសម្អាតដោយខ្លួនឯង។ សារធាតុរាវ ប្រែប្រួលក្នុងអំឡុងវដ្តនៃរដូវ និងក្នុងពេលមានផ្ទៃពោះផងដែរ។ សារធាតុរាវដែលថ្លា ពណ៌ស ឬលឿងបន្តិច គឺជារឿងធម្មតា ប៉ុន្តែប្រសិនបើវាមានច្រើនខុសធម្មតា, ឬបើវាមានពណ៌លឿងចាស់ បៃតង ឬពណ៌សខាប់, មានក្លិនអាក្រក់ ឬរមាស់ក្រហាយ នោះគេហៅថា "ធ្លាក់ស" ហើយវាអាចជាជំងឺកាមរោគដែរ។ ចូរស្វែងរកគ្រូពេទ្យចំពោះសញ្ញាមិនធម្មតា ឬមិនស្រួលខ្លួន។

មានបាក់តេរីប្រភេទល្អជាច្រើន លូតលាស់នៅក្នុងទ្វារមាស ដើម្បីរក្សាសុខភាពបានល្អ។ ភាពតប់ប្រមល់ខ្លាំងពេក ការលេបថ្នាំអង់ទីប៊ីយោទិក មានផ្ទៃពោះ និងលក្ខខណ្ឌផ្សេងទៀត ប៉ះពាល់ទៅលើបាក់តេរីទាំងនោះ ហើយធ្វើឲ្យងាយមានការបង្ករោគនៅក្នុងទ្វារមាស។ ចូរបង្ការជំងឺនៅក្នុងទ្វារមាសតាមរយៈការលាងសម្អាតដៃរៀងរាល់ថ្ងៃ និងចៀសវាងប្រើទឹកអប់ សាប៊ូក្រអូប ប្រដាប់ដុស ឬស្ព្រាយបាញ់ នៅលើតំបន់ប្រដាប់ភេទ ឬខាងក្នុងទ្វារមាស។ ការកាត់បន្ថយកាហ្វេ ស្រា និងអាហារឬភេសជ្ជៈផ្អែម អាចកាត់បន្ថយការបង្ករោគនៅក្នុងទ្វារមាស។

# ជំងឺរលាកទ្វារមាសដោយបាក់តេរី

ជំងឺរលាកទ្វារមាសដោយបាក់តេរី គឺជាការបង្ករោគដោយបាក់តេរីនៅក្នុងទ្វារមាស។ សាប៊ូ ទឹកអប់ ឬគ្រឿងក្រអូប ដែលដាក់ទៅក្នុងទ្វារមាស អាចធ្វើឲ្យងាយមានជំងឺរលាកទ្វារមាសដោយបាក់តេរី។ ប្រសិនបើការរួមភេទ ធ្វើឲ្យរមាស់ទ្វារមាស នោះវាកាន់តែងាយមានជំងឺរលាកទ្វារមាសដោយបាក់តេរី។ ជាធម្មតាវាមិនមានគ្រោះថ្នាក់ទេ ប៉ុន្តែវាអាចធ្វើឲ្យស្ត្រីមានផ្ទៃពោះ កើតកូនមិនគ្រប់ខែ ឬកូនឆ្លងរោគបន្ទាប់ពីកើត។

## រោគសញ្ញា

- ធ្លាក់សច្រើនខុសធម្មតា
- មានក្លិនអាក្រក់ដូចត្រី ចេញពីទ្វារមាស ជាពិសេសបន្ទាប់ពីរួមភេទរួច
- រមាស់តិចៗ

## ការព្យាបាល

ប្រើថ្នាំណាមួយក្នុងនេះ ៖ metronidazole (ទំព័រ 35) ជាថ្នាំលេប ឬស៊កចូលទ្វារមាស, tinidazole ជាថ្នាំលេប (ទំព័រ 37), ឬ clindamycin (ទំព័រ 33) ជាថ្នាំលេប ឬស៊កចូលទ្វារមាស។ បើជាស្ត្រីមានផ្ទៃពោះ ចូរប្រើថ្នាំលេប metronidazole ។



ចូរពិនិត្យមើលថ្នាំពេទ្យ ថាតើវាសម្រាប់លេប ឬសម្រាប់ដាក់ទៅក្នុងទ្វារមាស។

# មេរោគផ្សិត (Moniliasis, Candida, Thrush)



មេរោគផ្សិត ប៉ះពាល់ដល់ប្រដាប់ភេទ ហើយធ្វើឲ្យគេគិតថាវាជាជំងឺកាមរោគ ប៉ុន្តែជាធម្មតា មេរោគផ្សិត មិនឆ្លងតាមការរួមភេទនោះទេ។ តាមធម្មតា មេរោគផ្សិតមិនមានគ្រោះថ្នាក់ទេ ប៉ុន្តែអាចពិបាកក្នុងខ្លួនយ៉ាងខ្លាំង។ អ្នកងាយនឹងមានការបង្ករោគដោយមេរោគផ្សិតបំផុតនៅពេលមានផ្ទៃពោះ ពេលប្រើថ្នាំអង់ទីប៊ីយោទិក ឬមានជំងឺផ្សេងទៀតដូចជា ទឹកនោមផ្អែម ឬមេរោគអេដស៍។ មេរោគផ្សិតកើតឡើងញឹកញាប់បំផុតនៅលើស្ត្រី ប៉ុន្តែបុរសក៏អាចមានការបង្ករោគដោយមេរោគផ្សិតផងដែរ។ នៅលើបុរស វាអាចបណ្តាលឲ្យរលាកក្បាលលិង្គ និងរមាស់ពងស្វាស។ ទាំងបុរសនិងស្ត្រី សុទ្ធតែអាចមានមេរោគផ្សិតនៅបំពង់កដូចគ្នា។

មេរោគផ្សិតក៏អាចលេចឡើងនៅលើភ្លៅខាងក្នុង គ្លៀក នៅក្រោមសុដន់ ឬជុំវិញរន្ធគូថ។ មេរោគផ្សិតកើតឡើងញឹកញាប់បំផុតនៅកន្លែងដែលផ្នែកនៃរាងកាយ ប៉ះគ្នា ហើយមានការស្លៀកពាក់ជិត ដែលជាលក្ខខណ្ឌធ្វើឱ្យស្បែកមានសំណើមជានិច្ច។

### រោគសញ្ញានៅលើស្ត្រី

- សារធាតុដុំៗពណ៌ស ហូរចេញពីទ្វារមាស ដូចជាយ៉ាអ៊ួ
- ស្បែកឡើងពណ៌ក្រហមភ្លឺ ខាងក្រៅនិងខាងក្នុងទ្វារមាស ហើយអាចហូរឈាម
- មានអារម្មណ៍រមាស់ខ្លាំងនៅខាងក្នុងឬខាងក្រៅទ្វារមាស
- ក្រហាយនៅពេលនោម

### រោគសញ្ញានៅលើបុរស

- សារធាតុខាប់ ពណ៌ស ជាប់នៅនឹងផ្នត់នៃស្បែកលិង្គ និងក្រោមស្បែកដែលគ្របចុងលិង្គ
- ស្នាមកន្ទួលពណ៌ក្រហមនៅលើក្បាលលិង្គ
- រមាស់ ក្រហាយ ឬឡើងក្រហមនៅលើលិង្គ ឬពងស្វាស

### ការព្យាបាល

ជួនកាល ការបង្ករោគដោយមេរោគផ្សិត នឹងបាត់ទៅវិញដោយមិនចាំបាច់ប្រើថ្នាំពេទ្យ។ ការព្យាបាលបែបធម្មជាតិ អាចកាត់បន្ថយភាពរមាស់។

## ការព្យាបាលបែបធម្មជាតិ៖

ការលាងជម្រះសារធាតុរាវដោយទឹកស្អាត អាចជួយបាន។ ឬមួយលាយយ៉ាអ៊ួសុទ្ធ (មិនមានជាតិស្ករ ឬរសជាតិ) ឬទឹកខ្មេះ ¼ ពែង ក្នុងទឹកស្អាតក្តៅឧណ្ឌៗមួយចានដែក ។ អង្គុយត្រាំក្នុងទឹកនេះរយៈពេល ២០ ទៅ ៣០នាទី។ បើវាជួយអ្នកឱ្យមានអារម្មណ៍ធូរស្រាល សូមធ្វើបែបនេះ ២ដងក្នុងមួយថ្ងៃ។





ឬមួយលាយទឹកខ្មេះ ៣ស្លាបព្រាបាយ ជាមួយទឹកឆ្អិនត្រជាក់ ១លីត្រ។ ត្រាំបន្ទះក្រណាត់សំឡីស្អាត ក្នុងទឹកលាយនេះ រួចស៊កចូលក្នុងទ្វារមាសរៀងរាល់យប់ រយៈពេល ៣យប់។ យកក្រណាត់សំឡីចេញនៅពេលព្រឹក។ បុរសអាចធ្វើដូចគ្នានេះដែរ រួចយកក្រណាត់សំឡីគ្របដណ្ដប់លិង្គឬពងស្វាស។

## ការព្យាបាលដោយថ្នាំពេទ្យ៖

ប្រើថ្នាំណាមួយក្នុងចំណោមនេះ៖

ថ្នាំទឹកពណ៌ស្វាយ Gentian (ទំព័រ 38) នៅលើទ្វារមាស លិង្គ ឬពងស្វាស រៀងរាល់យប់ រយៈពេល ៧យប់

ឬ

ថ្នាំក្រែម Miconazole (ទំព័រ 39), ថ្នាំក្រែម nystatin (ទំព័រ 39), ឬថ្នាំក្រែម ឬថ្នាំគ្រាប់ clotrimazole (ទំព័រ 38) នៅលើឬក្នុងទ្វារមាស ឬលើលិង្គនិងពងស្វាស រៀងរាល់យប់ រយៈពេល ៧យប់។ ថ្នាំទាំងនេះមានសុវត្ថិភាពក្នុងការដាក់ក្នុងទ្វារមាសក្នុងអំឡុងពេលមានផ្ទៃពោះ។

បុរសប្រហែលជាត្រូវការពេលយូរជាងក្នុងការព្យាបាល។

### ការបង្ការ

ស្លៀកពាក់ខាងក្រៅនិងខាងក្នុងឲ្យរលុងៗ ដើម្បីឱ្យខ្យល់ចូលដល់ប្រដាប់ភេទ។ បែបនេះជួយបង្ការមេរោគផ្សិត។ បោកគក់ឬប្ដូរខោទ្រនាប់ឱ្យបានញឹកញាប់។ មិនត្រូវដាក់សាប៊ូទៅក្នុងទ្វារមាសទេនៅពេលងូតទឹក។ មិនត្រូវបាញ់ទឹកលាងទ្វារមាសទេ។ ប្រសិនបើអ្នកមានជំងឺទឹកនោមផ្អែមឬមេរោគអេដស៍ ការលេបថ្នាំបានត្រឹមត្រូវ និងការថែទាំសុខភាពរបស់អ្នក ជួយបង្ការបញ្ហាមេរោគផ្សិតបាន។

# ជំងឺទ្រីកូម៉ូណាស់ (Trich)

ជំងឺទ្រីកូម៉ូណាស់គឺជាការបង្ករោគដែលបណ្ដាលមកពីប៉ារ៉ាស៊ីតមួយ។ ចំពោះស្ត្រី វាធ្វើឲ្យពិបាកក្នុងខ្លួននិងរមាស់យ៉ាងខ្លាំង។ ជាទូទៅ បុរសមិនមានរោគសញ្ញាអ្វីទេ។ ប្រសិនបើការបង្ករោគមាននៅខាងលិង្គ វាអាចឆ្លងទៅស្ត្រីក្នុងពេលរួមភេទដោយមិនប្រើស្រោមអនាម័យ។

ជំងឺទ្រីកូម៉ូណាស់ មិនមានគ្រោះថ្នាក់នោះទេ ប៉ុន្តែវាអាចធ្វើឱ្យរមាស់ទ្វារមាសដែលធ្វើឲ្យស្ត្រីងាយឆ្លងជំងឺកាមរោគផ្សេងទៀត រួមទាំងមេរោគអេដស៍។



ការធ្លាក់សមានក្លិនអាក្រក់ជារឿយៗគឺជាជំងឺទ្រីកូម៉ូណាស់។

## រោគសញ្ញា

- ធ្លាក់សពណ៌ប្រផេះ លឿង ឬបៃតង
- ធ្លាក់សក្លិនអាក្រក់
- ទ្វារមាសឡើងក្រហមនិងរមាស់
- ឈឺចាប់ឬក្រហាយនៅពេលនោម

## ការព្យាបាល

លេបថ្នាំ metronidazole (ទំព័រ 35) ឬ tinidazole (ទំព័រ 37)។ ស្ត្រីមានផ្ទៃពោះមិនគួរលេបថ្នាំ tinidazole នោះទេ។

ព្យាបាលដៃគូរបស់គាត់ ដោយប្រើថ្នាំដូចគ្នា។ ដើម្បីឱ្យមានអារម្មណ៍ធូរស្រាល សូមអង្គុយក្នុងចានដែកដែលមានទឹកស្អាតក្តៅឧណ្ហៗ រយៈពេល ១៥នាទី ឱ្យបានញឹកញាប់បំផុត។ បែបនេះជួយបន្ថយការឈឺចាប់នៅប្រដាប់ភេទ ហើយវានឹងបង្កើនល្បឿននៃការសះស្បើយ។ ជៀសវាងការរួមភេទ រហូតទាល់តែអ្នកនិងដៃគូរបស់អ្នក បានបញ្ចប់ការព្យាបាល ហើយរោគសញ្ញាបានបាត់អស់។

# ជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា

ទាំងបុរសនិងស្ត្រីអាចកើតជំងឺប្រមេះទឹកបាយ និងប្រមេះទឹកថ្លា បើទោះជាពួកគេគ្មានរោគសញ្ញាក៏ដោយ។ ប្រសិនបើជំងឺប្រមេះទឹកបាយ ឬប្រមេះទឹកថ្លា មិនត្រូវបានព្យាបាលទេ នោះវាអាចបណ្ដាលឲ្យមានជំងឺធ្ងន់ធ្ងរ ឬមានភាពអារលើស្ត្រីនិងបុរស។

គ្រប់ស្ត្រីមានផ្ទៃពោះទាំងអស់ គួរត្រូវបានធ្វើតេស្តរកជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា ព្រោះទារករបស់គាត់អាចឆ្លងមេរោគនេះក្នុងអំឡុងពេលកើត។ ប្រសិនបើតេស្តបង្ហាញថាគាត់មានជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា ឬទាំងពីរ នោះទាំងគាត់និងដៃគូរបស់គាត់ គួរទទួលការព្យាបាល។ ប្រសិនបើគាត់ ឬដៃគូរបស់គាត់ មានរោគសញ្ញានៃជំងឺនេះ ប៉ុន្តែមិនអាចរកការធ្វើតេស្តបាន គួរតែព្យាបាលពួកគេដដែល។ ជំងឺប្រមេះទឹកបាយ និងប្រមេះទឹកថ្លា មានរោគសញ្ញាស្រដៀងៗគ្នា។

## រោគសញ្ញានៅលើស្ត្រី

- ហូរសារធាតុរាវពណ៌លឿងឬបៃតងពីទ្វារមាស ឬរន្ធគូថ
- ឈឺចាប់នៅក្នុងពោះផ្នែកខាងក្រោម
- គ្រុនក្ដៅ
- ឈឺចាប់ក្នុងពេលរួមភេទ
- ឈឺចាប់ឬក្រហាយពេលនោម

ប្រសិនបើស្ត្រីមានជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា ហើយក៏មានគ្រុនក្ដៅនិងឈឺចាប់ក្នុងពោះផ្នែកខាងក្រោមដែរ នោះគាត់ប្រហែលជាមាន ជំងឺរលាកអាងត្រគាក (មើលទំព័រ 11)។

## រោគសញ្ញានៅលើបុរស



- ហូរទឹកឬខ្ទុះពីលិង្គឬរន្ធគូថ
- ឈឺហើមពងស្វាស
- ឈឺចាប់ឬក្រហាយពេលនោម

ចំពោះបុរស រោគសញ្ញាដំបូងៗចាប់ផ្ដើមនៅ ២ ទៅ ៥ថ្ងៃ (ឬរហូតដល់ ៣សប្ដាហ៍ ឬយូរជាងនេះ) បន្ទាប់ពីរួមភេទជាមួយអ្នកដែលមានជំងឺ។ រីឯស្ត្រីវិញ រោគសញ្ញាអាចមិនបង្ហាញឡើងរហូតច្រើនសប្ដាហ៍ឬច្រើនខែ។ ប៉ុន្តែមនុស្សដែលមិនមានរោគសញ្ញាអ្វីទាំងអស់ ក៏នៅតែអាចចម្លងជំងឺទៅអ្នកដទៃទៀតដែរ ដោយចាប់ផ្ដើមពីរបីថ្ងៃបន្ទាប់ពីការឆ្លង។

## ការព្យាបាល

ការព្យាបាលមានផលល្អបំផុតនៅពេលចាប់ផ្ដើមបានឆាប់។ ត្រូវប្រាកដថាអ្នកលេបថ្នាំទាំងអស់ បើទោះជាអ្នកចាប់ផ្ដើមមានអារម្មណ៍ធូរស្រាលក៏ដោយ។ ព្យាបាលដៃគូរបស់អ្នកជំងឺ ដោយប្រើថ្នាំដូចគ្នា។

ជាការល្អបំផុតគួរព្យាបាលទាំងជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា លុះត្រាតែការធ្វើតេស្ដបញ្ជាក់ថាគាត់មានជំងឺតែមួយប៉ុណ្ណោះ។ ការប្រើថ្នាំផ្សំ ២មុខសម្រាប់ជំងឺប្រមេះទឹកបាយ ក៏នឹងព្យាបាលជំងឺប្រមេះទឹកថ្លាផងដែរ។ ប្រសិនបើតេស្ដបង្ហាញថាមានជំងឺប្រមេះទឹកថ្លា ប៉ុន្តែគ្មានជំងឺប្រមេះទឹកបាយទេ នោះត្រូវការប្រើថ្នាំតែមួយប៉ុណ្ណោះ។ តារាងនៅ ទំព័រ 42 ក្នុងផ្នែក ការរួមផ្សំថ្នាំដើម្បីព្យាបាលជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា បង្ហាញការផ្សំនិងការព្យាបាលផ្សេងៗគ្នា អាស្រ័យលើថ្នាំដែលមាន។

ដោយសារជំងឺប្រមេះទឹកបាយ កំពុងតែស៊ាំនឹងថ្នាំអង់ទីប៊ីយោទិកយ៉ាងខ្លាំង ដូច្នេះល្អបំផុតគួរសួរដំបូន្មានពីបុគ្គលិកសុខាភិបាលក្នុងតំបន់ ថាតើថ្នាំណាដែលមានប្រសិទ្ធិភាព, ថ្នាំណាអាចរកបាន និងមានតំលៃសមរម្យនៅក្នុងតំបន់របស់អ្នក។ ប្រសិនបើការហូរទឹកនិងការឈឺចាប់ មិនបាត់ទៅវិញក្នុងរយៈពេល ២ ឬ ៣ថ្ងៃបន្ទាប់ពីចាប់ផ្ដើមការព្យាបាលទេ វាអាចមានន័យថាជំងឺប្រមេះទឹកបាយ ស៊ាំនឹងថ្នាំ ហើយត្រូវការប្រើថ្នាំផ្សេងទៀត។

# ជំងឺរលាកអាងត្រគាក (PID)



ជំងឺរលាកអាងត្រគាក គឺជាឈ្មោះសម្រាប់ការបង្ករោគនៅផ្នែកណាមួយនៃការបន្តពូជ នៅក្នុងផ្នែកក្រោមពោះរបស់ស្ត្រី។ ជារឿយៗ វាត្រូវបានហៅថា "ជំងឺអាងត្រគាក" ។

ជំងឺអាងត្រគាកអាចកើតឡើងប្រសិនបើអ្នកមានជំងឺកាមរោគដែលមិនបានព្យាបាលសះស្បើយ ជាពិសេសជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា។ ប៉ុន្តែមិនមែនជំងឺអាងត្រគាកទាំងអស់សុទ្ធតែបណ្ដាលមកពីជំងឺកាមរោគនោះទេ។ មូលហេតុដទៃទៀតនៃជំងឺអាងត្រគាក មានដូចជា ការឆ្លងរោគក្រោយសម្រាល ការរលូតកូន និងការរំលូតកូន ឬករណីកម្រ គឺដោយសារតែកងដាក់ក្នុងស្បូនដែលត្រូវគេដាក់ចូលដោយមិនបានអនុវត្តតាមគោលការណ៍រម្ងាប់មេរោគ។

មេរោគដែលបង្កជំងឺអាងត្រគាក ធ្វើដំណើរពីទ្វារមាស ឆ្លងតាមមាត់ស្បូន ចូលទៅក្នុងស្បូន ដៃស្បូន និងអូវែ។ ប្រសិនបើមិនបានព្យាបាលទាន់ពេលទេ វាអាចបណ្ដាលឲ្យមានការឈឺចាប់រ៉ាំរ៉ៃ មានភាពអារ ឈឺធ្ងន់ធ្ងរ ឬស្លាប់។

## រោគសញ្ញា (អ្នកអាចមានមួយឬច្រើនក្នុងនេះ)

- ឈឺចាប់ក្នុងផ្នែកខាងក្រោមនៃពោះ(អាងត្រគាក) - វាអាចមានសភាពស្រាល ឬធ្ងន់
- ឈឺចាប់ឬហូរឈាមក្នុងពេលរួមភេទ
- មានសភាពទន់នៅពេលអ្នកចុចពីលើពោះផ្នែកខាងក្រោម
- គ្រុនក្ដៅ
- មានអារម្មណ៍ថាឈឺធ្ងន់ និងខ្សោយជាខ្លាំង
- ហូរឈាមខុសធម្មតា ឬធ្លាក់សធុំក្លិនអាក្រក់ពីទ្វារមាស

## ការព្យាបាល

ជំងឺនេះជាទូទៅត្រូវបានបង្កឡើងដោយមេរោគច្រើន, ដូច្នេះចាំបាច់ត្រូវការថ្នាំពេទ្យ ៣ប្រភេទ។ មើលផ្នែកការរួមផ្សំថ្នាំដើម្បីព្យាបាលជំងឺអាងត្រគាក នៅ ទំព័រ 43។

ចាប់ផ្ដើមការព្យាបាលភ្លាមៗ។ ប្រសិនបើអ្នកមិនមានអារម្មណ៍ធូរស្រាលបន្ទាប់ពី ២ថ្ងៃ និង ២យប់ (៤៨ម៉ោង), ឬបើអ្នកឈឺធ្ងន់ និងមានគ្រុនក្ដៅខ្លាំង ឬក្អួត, ឬបើអ្នកមានផ្ទៃពោះ ឬទើបតែរំលូតកូន ឬសម្រាលកូន, សូមទៅមណ្ឌលសុខភាពឬមន្ទីរពេទ្យជាបន្ទាន់។ អ្នកនឹងត្រូវការថ្នាំចាក់តាមសរសៃ (IV) ។

ប្រសិនបើអ្នកមានជំងឺរលាកអាងត្រគាក ដៃគូរបស់អ្នកក៏ត្រូវការធ្វើតេស្តរកនិងព្យាបាលជំងឺនេះផងដែរ។

# ជំងឺស្វាយ និងជំងឺដំបៅប្រដាប់ភេទ

ជំងឺស្វាយគឺជាជំងឺកាមរោគដ៏ធ្ងន់ធ្ងរមួយដែលយូរៗទៅនឹងប៉ះពាល់ដល់រាងកាយទាំងមូល។ រោគសញ្ញាដំបូង គឺដំបៅដែលមិនឈឺចាប់ ហើយបាត់ទៅវិញ។ ប្រសិនបើអ្នកជំងឺមិនបានកត់សម្គាល់វាទេ ហើយមិនបានទទួលការព្យាបាលទេ ជំងឺស្វាយនឹងស្ថិតនៅក្នុងខ្លួន។ ស្ត្រីមានផ្ទៃពោះទាំងអស់គួរធ្វើតេស្ដ៍រកជំងឺស្វាយ រួចព្យាបាលវាដើម្បីកុំឲ្យឆ្លងទៅទារក និងធ្វើឱ្យទារកកើតមិនគ្រប់ខែ, មានពិការភាពរាងកាយ ឬស្លាប់។ ប្រសិនបើអ្នកមានផ្ទុកមេរោគអេដស៍ឬជំងឺកាមរោគផ្សេងទៀត ជាញឹកញាប់បុគ្គលិកសុខាភិបាលនឹងធ្វើតេស្ដ៍រកជំងឺស្វាយផងដែរ។

ជំងឺដំបៅប្រដាប់ភេទគឺជាជំងឺកាមរោគដែលបង្កឡើងដោយបាក់តេរី ហើយវាធ្វើឲ្យមានដំបៅដ៏ឈឺចាប់នៅលើប្រដាប់ភេទ និងហើមកូនកណ្ដុរ និងឈឺចាប់។ ដូចជំងឺស្វាយដែរ ប្រសិនបើឆាប់ព្យាបាល វាអាចជាសះស្បើយដោយប្រើថ្នាំពេទ្យ។

ប្រសិនបើអ្នកមិនប្រាកដថាគាត់មានជំងឺស្វាយ ឬជំងឺដំបៅប្រដាប់ភេទ ឬទាំងពីរ សូមព្យាបាលសម្រាប់ជំងឺទាំងពីរតែម្ដង។ ម្យ៉ាងទៀត ត្រូវព្យាបាលជំងឺទាំងពីរដែរ ប្រសិនបើតេស្ដ៍បង្ហាញថាមានជំងឺទាំងពីរ ឬបើជំងឺទាំងពីរឃើញមានកើតឡើងញឹកញាប់នៅក្នុងតំបន់របស់អ្នក។ មើលផ្នែក ការរួមផ្សំថ្នាំសម្រាប់ព្យាបាលទាំងជំងឺស្វាយនិងជំងឺដំបៅប្រដាប់ភេទ, នៅទំព័រ 44។ ព្យាបាលដៃគូរបស់គាត់ដោយប្រើថ្នាំដូចគ្នា។

ជំងឺផ្សេងៗទៀតអាចឆ្លងតាមដំបៅនៅលើប្រដាប់ភេទបានយ៉ាងងាយ ជាពិសេសជំងឺរលាកថ្លើមប្រភេទបេ មេរោគអេដស៍ និងជំងឺកាមរោគដទៃទៀត។ ដើម្បីបង្ការការឆ្លងឬចម្លងជំងឺទាំងនេះ ចូរព្យាបាលវា និងចៀសវាងការរួមភេទរហូតទាល់តែសះដំបៅ។

រក្សាដំបៅឲ្យស្អាត ក្នុងពេលដែលវាកំពុងសះ។ លាងសម្អាតដំបៅរៀងរាល់ថ្ងៃដោយសាប៊ូនិងទឹក ហើយសម្អាតវាដោយប្រុងប្រយ័ត្ន។ មិនត្រូវឲ្យនរណាម្នាក់ប្រើក្រណាត់ដែលអ្នកបានជូតដំបៅឡើយ។



ដំបៅនៃជំងឺស្វាយ ឬជំងឺដំបៅប្រដាប់ភេទ នៅលើលិង្គបុរស



ដំបៅ នៃជំងឺស្វាយ ឬជំងឺដំបៅប្រដាប់ភេទ នៅលើប្រដាប់ភេទស្ត្រី

ទោះបីជាជំងឺស្វាយ និងជំងឺដំបៅប្រដាប់ភេទ សុទ្ធតែចាប់ផ្តើមដោយមានដំបៅក៏ដោយ តែជាទូទៅដំបៅពីជំងឺស្វាយ មិនឈឺចាប់ទេ។ ដំបៅនៃជំងឺដំបៅប្រដាប់ភេទ ជាទូទៅមានភាពឈឺចាប់។

## រោគសញ្ញានៃជំងឺស្វាយ

ជាធម្មតា រោគសញ្ញាដំបូងគឺដំបៅតូចមួយដែលមិនឈឺចាប់ ហៅថា ទាមឡា ហើយវាលេចឡើងនៅ ២ ទៅ ៥សប្តាហ៍បន្ទាប់ពីរួមភេទជាមួយអ្នកដែលមានជំងឺស្វាយ។ ទាមឡា ដំបូងៗមើលដូចជាដុំមួយ បន្ទាប់មកវាក៏បែកក្លាយជាដំបៅ។ ជាទូទៅវាលេចឡើងនៅក្នុងតំបន់ប្រដាប់ភេទ ហើយក៏អាចចេញនៅលើមាត់ ឬរន្ធគូថផងដែរ។ ចំពោះស្ត្រីវិញ ដំបៅអាចចេញនៅក្នុងទ្វារមាស ហើយមិនដឹងខ្លួនទេ។

ដំបៅកើតឡើងរយៈពេលពីរបីថ្ងៃ ទៅពីរបីសប្តាហ៍ បន្ទាប់មកក៏បាត់ទៅវិញដោយគ្មានការព្យាបាល។ ច្រើនសប្តាហ៍ឬច្រើនខែបន្ទាប់មក អាចនឹងមានកន្ទួល (ជាពិសេសនៅបាតដៃ និងបាតជើង) ឈឺក គ្រុនក្តៅស្រាល ឬឈឺមាត់។ រាល់កន្ទួលឬបញ្ហាស្បែកទាំងឡាយដែលលេចឡើងច្រើនថ្ងៃឬច្រើនសប្តាហ៍បន្ទាប់ពីមានដំបៅនៅលើប្រដាប់ភេទ គឺវាអាចជាជំងឺស្វាយ។ ចូរធ្វើតេស្តនិងព្យាបាលឲ្យបានឆាប់។ បើមិនព្យាបាលទេ ជំងឺស្វាយអាចរាលដាលទៅដល់ផ្នែកដទៃទៀតនៃរាងកាយ ធ្វើឲ្យមានជំងឺបេះដូង ខ្វិន ខ្សោយបញ្ញា និងសូម្បីតែស្លាប់។ ដោយសារតែជំងឺស្វាយមានគ្រោះថ្នាក់ខ្លាំង ប្រទេសជាច្រើនមានកម្មវិធីធ្វើតេស្តដោយឥតគិតថ្លៃ។

## ការព្យាបាលជំងឺស្វាយ

ការព្យាបាលល្អបំផុតគឺថ្នាំ benzathine penicillin ចាក់សាច់ដុំ (ទំព័រ 31)។ ប្រសិនបើមិនអាចរកបានទេ ឬអ្នកជំងឺមានអាល់ឡែស៊ីនឹងថ្នាំ penicillin ចូរផ្តល់ថ្នាំលេប doxycycline (ទំព័រ 33)។ អាចប្រើថ្នាំ Erythromycin (ទំព័រ 34) ផងដែរ ប៉ុន្តែវាមិនមានប្រសិទ្ធភាពដូចគ្នាទេ ហើយដូសថ្នាំអាចធ្វើទុក្ខក្រពះ។ ស្ត្រីដែលមានផ្ទៃពោះ គួរស្វែងរកការព្យាបាលនៅគ្លីនិកឬមន្ទីរពេទ្យ។

## រោគសញ្ញានៃជំងឺដំបៅប្រដាប់ភេទ

ដំបៅពីជំងឺស្វាយនិងជំងឺដំបៅប្រដាប់ភេទ អាចមើលទៅដូចគ្នា ប៉ុន្តែប្រសិនបើដំបៅមានភាពឈឺចាប់ និងហូរឈាមយ៉ាងងាយ នោះវាអាចជាជំងឺដំបៅប្រដាប់ភេទ។ រោគសញ្ញាដទៃទៀតនៃជំងឺដំបៅប្រដាប់ភេទ គឺការហើមក្រលៀន និងគ្រុនក្តៅស្រាល។

## ការព្យាបាលជំងឺដំបៅប្រដាប់ភេទ

ការព្យាបាលល្អបំផុតគឺថ្នាំលេប azithromycin (ទំព័រ 30)។ ឬមួយប្រើមួយក្នុងចំណោមនេះ ៖
ថ្នាំ ceftriaxone ចាក់សាច់ដុំ (ទំព័រ 32), ឬថ្នាំលេប ciprofloxacin (ទំព័រ 32) ឬ erythromycin (ទំព័រ 34)។

# ពងបែកលើប្រដាប់ភេទ



ពងបែកនៃជំងឺពងបែកលើប្រដាប់ភេទ

ពងបែកលើប្រដាប់ភេទ គឺជាជំងឺកាមរោគដែលបណ្តាលមកពីមេរោគ។ មិនមានការព្យាបាលឲ្យជាសះស្បើយសម្រាប់ជំងឺពងបែកលើប្រដាប់ភេទនោះទេ ប៉ុន្តែការព្យាបាលអាចធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្រាល។

ជំងឺពងបែកលើប្រដាប់ភេទ ធ្វើឲ្យមានពងបែកដ៏ឈឺចាប់នៅលើប្រដាប់ភេទ ឬរន្ធគូថ ដែលវាកើតបាត់ៗរយៈពេលជាច្រើនខែឬច្រើនឆ្នាំ។ ដំបៅអាចរាលដាលទៅដល់មាត់ ក្នុងពេលរួមភេទតាមមាត់។ (ដំបៅមាត់ខ្លះ, ហៅថាដំបៅត្រជាក់, បណ្តាលមកពីប្រភេទផ្សេងៗនៃជំងឺពងបែកលើប្រដាប់ភេទ)។



ជំងឺពងបែកនៅប្រដាប់ភេទ អាចឆ្លងពីម្តាយទៅទារក ប្រសិនបើម្តាយមានដំបៅនៃជំងឺនេះនៅក្នុងទ្វារមាសក្នុងអំឡុងពេលសម្រាលកូន។ ស្ត្រីដែលកំពុងឈឺពោះសម្រាលកូន និងមានដំបៅនៃជំងឺពងបែកនៅប្រដាប់ភេទ គួរតែសម្រាលកូននៅមន្ទីរពេទ្យ ដែលជាទូទៅគឺប្រើមធ្យោបាយសម្រាលកូនដោយវះកាត់។ សូមព្យាបាលម្តាយក្នុងខែចុងក្រោយនៃផ្ទៃពោះ ដើម្បីបង្ការកុំឱ្យដំបៅឆ្លងទៅទារកក្នុងអំឡុងពេលសម្រាល។

ជំងឺផ្សេងៗទៀតអាចឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតបានយ៉ាងងាយតាមរយៈដំបៅនៃប្រដាប់ភេទ ជាពិសេសជំងឺរលាកថ្លើមប្រភេទបេ មេរោគអេដស៍ និងជំងឺកាមរោគផ្សេងៗទៀត។ ដើម្បីបង្ការការចម្លងឬឆ្លងជំងឺទាំងនេះ ចូរព្យាបាលវា និងចៀសវាងការរួមភេទរហូតទាល់តែដំបៅជាសះ។

## រោគសញ្ញា

- ឈឺផៀបៗ រមាស់ ឬមានអារម្មណ៍ឈឺចាប់លើស្បែកនៃប្រដាប់ភេទ ឬករណើកម្រ គឺនៅលើភ្លៅ
- ពងបែកតូចៗដែលបែកនិងកើតជាដំបៅចំហដ៏ឈឺចាប់នៅលើប្រដាប់ភេទ

លើកដំបូងដែលអ្នកមានដំបៅនៃជំងឺពងបែកនៅប្រដាប់ភេទ វាអាចមានរយៈពេល ៣សប្តាហ៍ ឬយូរជាងនេះ។ អ្នកអាចមានគ្រុនក្តៅ ឈឺក្បាល ឈឺខ្លួន ញាក់ ឬហើមកូនកណ្តុរនៅក្នុងក្រលៀន។ ការឆ្លងរោគលើកក្រោយ ជាទូទៅមិនអាក្រក់ដូចលើកដំបូងនោះទេ។ នៅពេលដែលមនុស្សម្នាក់មានមេរោគ នោះដំបៅអាចលេចឡើងជាច្រើនដង។ សូមមើលពី របៀបធ្វើឲ្យមានអារម្មណ៍ធូរស្រាល ក្នុងពេលសះពីជំងឺកាមរោគ, ទំព័រ 19។

## ការព្យាបាល

មិនមានការព្យាបាលសះស្បើយសម្រាប់ជំងឺពងបែកនៅប្រដាប់ភេទទេ ប៉ុន្តែថ្នាំ acyclovir (ទំព័រ 40) ធ្វើឲ្យជំងឺធូរស្រាល និងមិនសូវឈឺចាប់។

ការបង្ការ

កាត់បន្ថយការឆ្លងរាលដាលនៃជំងឺពងបែកនៅប្រដាប់ភេទ តាមរយៈការមិនរួមភេទនៅពេលមានដំបៅ។ ការពាក់ស្រោមអនាម័យដែលគ្របជិតពីលើដំបៅ អាចកាត់បន្ថយការចម្លងជំងឺ។ ស្រោមអនាម័យស្ត្រី អាចមានប្រសិទ្ធភាពកាន់តែល្អ ព្រោះវាគ្របលើប្រដាប់ភេទបានច្រើនជាង។

ត្រូវលាងដៃជាមួយសាប៊ូនិងទឹកជានិច្ច បន្ទាប់ពីបានប៉ះពាល់ដំបៅ ដើម្បីកុំឲ្យម្រាមដៃរបស់អ្នក ចម្លងជំងឺទៅអ្នកដទៃក្នុងគ្រួសារ។

# ជំងឺសិរមាន់

ជំងឺសិរមាន់ បង្កឡើងដោយមេរោគ។ សិរមាន់នៅលើប្រដាប់ភេទ មានសភាពទន់ជាងសិរមាន់នៅលើផ្នែកផ្សេងទៀតនៃរាងកាយ ហើយជាទូទៅវាមានច្រើន។ សិរមាន់ក៏អាចមាននៅក្នុងទ្វារមាស ឬខាងក្រោមស្បែកដែលគ្របចុងលិង្គផងដែរ ហើយមិនដឹងខ្លួនទេ។ ទោះបីសិរមាន់អាចនឹងបាត់ទៅវិញមែន ជាទូទៅវាកាន់តែធ្ងន់ធ្ងរទៅ ហើយគួរតែព្យាបាលវា។ ដោយសារតែជំងឺសិរមាន់ អាចមើលទៅដូចនឹងរោគសញ្ញាដំបូងនៃជំងឺស្វាយដែរ ដូច្នេះសូមធ្វើតេស្តរកជំងឺស្វាយ មុននឹងព្យាបាលជំងឺសិរមាន់, ហើយបើវាជាជំងឺស្វាយមែន ត្រូវព្យាបាលជាបន្ទាន់។

សិរមាន់ លូតលាស់លឿននៅពេលមានផ្ទៃពោះ និងអាចហូរឈាមក្នុងពេលសម្រាលកូន ដែលវាអាចឆ្លងទៅទារក។ ស្ត្រីមានផ្ទៃពោះដែលមានជំងឺសិរមាន់ គួរពិគ្រោះជាមួយបុគ្គលិកសុខាភិបាល ដើម្បីមើលថាតើគាត់គួរតែសម្រាលកូននៅមន្ទីរពេទ្យដោយការវះកាត់ដែរឬទេ ។

រោគសញ្ញា



- សាច់ដុះតូចៗ រឹង ពណ៌សឬត្នោត មានផ្ទៃគ្រើម។ ចំពោះស្ត្រី វា ដុះនៅលើបបូរនៃទ្វារមាស, នៅខាងក្នុងទ្វារមាស, ឬនៅជុំវិញរន្ធគូថ។ ចំពោះបុរស ជាធម្មតា វាដុះនៅលើលិង្គ ប៉ុន្តែក៏អាចដុះនៅលើពងស្វាស ឬរន្ធគូថផងដែរ។
- ជួនកាលសិរមាន់រមាស់



ការព្យាបាល

ជាទូទៅ គេចាំបាច់ផ្តល់ការព្យាបាលជាច្រើន ក្នុងមួយសប្តាហ៍ម្តង។ តាមធម្មតា បុគ្គលិកសុខាភិបាលអនុវត្តការព្យាបាលលើកទី១ ហើយអាចនឹងបង្ហាញអ្នកពីរបៀបព្យាបាលនៅផ្ទះ ឬឲ្យ ត្រឡប់មកព្យាបាលវិញ។ ថ្នាំពេទ្យរួមមាន trichloroacetic acid (TCA), bichloracetic acid (BCA), ឬ podofilox, មើលទំព័រ 40 ទៅ 41។



ការបង្ការ

ចូរពាក់ស្រោមអនាម័យក្នុងពេលរួមភេទ ប្រសិនបើអ្នក ឬដៃគូរបស់អ្នក មានជំងឺសិរមាន់ ឬជៀសវាងការរួមភេទរហូតបាត់សិរមាន់អស់។ វ៉ាក់សាំងដែលបង្ការវីរុស Human Papilloma Virus (HPV) អាចជួយបង្ការជំងឺសិរមាន់ដែរ។

# មេរោគ Human Papilloma Virus (HPV)

មេរោគ HPV មានច្រើនប្រភេទ។ មេរោគ HPV ប្រភេទខ្លះ បណ្តាលឲ្យមានជំងឺសិរមាន់ (ទំព័រ 15) ។ មេរោគ HPV ពីរបីប្រភេទទៀត មានគ្រោះថ្នាក់កាន់តែខ្លាំង ហើយអាចបង្កជាជំងឺមហារីកមាត់ស្បូន មហារីកបំពង់ក ឬមហារីកក្នុងរន្ធគូថ។ មនុស្សភាគច្រើនដែលមានមេរោគ HPV មិនមានរោគសញ្ញាដែលអាចមើលឃើញនឹងភ្នែកនោះទេ។



សំណាកដែលជូតពីមាត់ស្បូន ត្រូវបានប្រើសម្រាប់ធ្វើតេស្តមេរោគ HPV ។

ការធ្វើតេស្តរកមើលតាមធម្មតា អាចបង្ហាញថាតើមានកោសិកាមិនប្រក្រតីនៅលើមាត់ស្បូនដែលបង្កដោយមេរោគ HPV ដែរ ឬទេ។ ប៉ុន្តែបើទោះបីជាការធ្វើតេស្ត រកឃើញមេរោគ HPV ក៏ដោយ ក៏មិនមែនមានន័យថាមានជំងឺមហារីកនោះដែរ។

ការព្យាបាលដែលគ្មានការឈឺចាប់ និងមានសុវត្ថិភាព ហៅថា ការព្យាបាលដោយប្រើភាពត្រជាក់ (cryotherapy) បង្កក និងសម្លាប់កោសិកាមិនប្រក្រតីនៅលើមាត់ស្បូន ដើម្បីកុំឲ្យវាវិវឌ្ឍន៍ទៅជាមហារីក។ សម្រាប់ព័ត៌មានបន្ថែមអំពីការធ្វើតេស្ត និងការព្យាបាលជំងឺមហារីកស្បូន សូមមើល ជំពូកស្តីពី ជំងឺមហារីក, ទំព័រ 12។

វ៉ាក់សាំងអាចការពារពីមេរោគ HPV ប្រភេទដ៏គ្រោះថ្នាក់បំផុត រួមទាំងប្រភេទដែលភាគច្រើនបង្កជំងឺសិរមាន់។ ការផ្តល់វ៉ាក់សាំងជាបន្តបន្ទាប់ ដែលជាទូទៅនៅចន្លោះអាយុ ៩ និង ២៦ឆ្នាំ អាចបង្ការមិនឲ្យឆ្លង ឬចម្លងមេរោគ HPV ដែលវាអាចបណ្តាលឲ្យកើតជំងឺមហារីក។ សូមមើលជំពូក វ៉ាក់សាំងអាចបង្ការជំងឺ, ទំព័រ 10។

# ជំងឺរលាកថ្លើមប្រភេទ B និង ជំងឺរលាកថ្លើមប្រភេទ C

ជំងឺរលាកថ្លើម ជាញឹកញាប់បង្កដោយមេរោគ។ ជំងឺរលាកថ្លើម មានច្រើនប្រភេទ។ ជំងឺរលាកថ្លើមប្រភេទ B និងជំងឺរលាកថ្លើមប្រភេទ C អាចឆ្លងតាមរយៈការរួមភេទ ឬឈាម។ ជំងឺរលាកថ្លើមប្រភេទ B ចម្លងរាលដាលយ៉ាងងាយពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត ជាពិសេសក្នុងពេលរួមភេទ។ ជំងឺរលាកថ្លើមប្រភេទ C ងាយនឹងឆ្លងតាមរយៈការប៉ះពាល់ឈាមនិងឈាម ហើយមិនសូវឆ្លងតាមការរួមភេទតែមួយមុខនោះទេ។ ការរួមភេទក្នុងពេលមានរដូវ ឬនៅពេលមានជំងឺកាមរោគដទៃមួយទៀត ជាពិសេសមេរោគអេដស៍ នោះវាកាន់តែងាយឆ្លងជំងឺរលាកថ្លើមប្រភេទ C តាមរយៈការរួមភេទ។ ជំងឺរលាកថ្លើមប្រភេទ B និងប្រភេទ C អាចបណ្តាលឲ្យខូចថ្លើមជាអចិន្ត្រៃយ៍ មហារីកថ្លើម និងសូម្បីតែស្លាប់។ ជំងឺរលាកថ្លើមប្រភេទ C គឺជាមូលហេតុចម្បងនៃការស្លាប់របស់អ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍។

ទាំងជំងឺរលាកថ្លើមប្រភេទ B និងប្រភេទ C សុទ្ធតែអាចចម្លងទៅទារកនៅក្នុងស្បូន។

## រោគសញ្ញានៃជំងឺរលាកថ្លើមប្រភេទ B

- មិនឃ្លានអាហារ
- អស់កម្លាំង និងខ្សោយ
- ភ្នែកលឿង ហើយជូនកាលស្បែកលឿង (ជាពិសេសនៅបាតដៃ និងបាតជើង)
- ឈឺនៅក្នុងពោះ ឬចង្អោរ
- ទឹកនោមពណ៌ត្នោត ដូចកូឡា និងលាមកពណ៌ស




ប្រហែលជាគ្មានរោគសញ្ញានៃជំងឺរលាកថ្លើមប្រភេទ B និងជំងឺរលាកថ្លើមប្រភេទ C ប៉ុន្តែជំងឺទាំងនេះបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ថ្លើម។

## រោគសញ្ញានៃជំងឺរលាកថ្លើមប្រភេទ C

ដូចគ្នានឹងរោគសញ្ញានៃជំងឺរលាកថ្លើមប្រភេទ B ដែរ ឬក៏មិនមានរោគសញ្ញារហូតដល់ច្រើនឆ្នាំក្រោយពីឆ្លងមេរោគ។

មនុស្សជាច្រើនមិនទាំងដឹងថាខ្លួនមានជំងឺនេះផង រហូតដល់ពួកគេបានធ្វើតេស្ត៍។

## ការព្យាបាល

ឥឡូវនេះមានថ្នាំដែលអាចព្យាបាលជំងឺរលាកថ្លើមប្រភេទ B និងប្រភេទ C ហើយថែមទាំងអាចព្យាបាលឲ្យជាសះស្បើយពីជំងឺរលាកថ្លើមប្រភេទ C ទៀតផង ។ ការជាសះស្បើយពីជំងឺរលាកថ្លើមប្រភេទ C មិនអាចការពារអ្នកមិនឲ្យកើតទៀតនោះទេ ប្រសិនបើអ្នកប្រឈមនឹងវា។ សូមធ្វើតេស្ត៍នៅមណ្ឌលសុខភាពរបស់អ្នក ដើម្បីរកមើលថាតើជំងឺរលាកថ្លើមប្រភេទណាដែលអ្នកប្រហែលជាមាន និងថាតើមានថ្នាំពេទ្យអ្វីខ្លះដែលអាចរកបាន។ សូម្បីតែគ្មានថ្នាំពេទ្យក៏ដោយ អ្នកនៅតែអាចមានអារម្មណ៍ធូរស្រាល និងជួយឱ្យថ្លើមសះស្បើយ តាមរយៈការសម្រាកឱ្យបានច្រើន, និងផឹកទឹកផ្លែឈើ ទឹកស៊ុបពីសាច់ និងស៊ុបបន្លែ ។ ដើម្បីគ្រប់គ្រងចង្អោរនិងក្អួត សូមក្រេបទឹកសូដា ទឹកខ្ញី ឬទឹកតែ ដូចជាតែ chamomile ជាដើម។ ប៉ុន្តែមិនត្រូវផឹកស្រាទេ។ សូម្បីតែជាតិអាល់កុលតែបន្តិចបន្តួច ក៏នឹងធ្វើឱ្យខូចខាតដល់ថ្លើមរបស់អ្នកថែមទៀត ហើយធ្វើឱ្យអ្នកមានអារម្មណ៍កាន់តែធ្ងន់ធ្ងរ។ កុំប្រើថ្នាំប៉ារ៉ាសេតាម៉ុល (acetaminophen ឬ Tylenol) ឬថ្នាំដែលមានជាតុផ្សំនេះ ព្រោះវាអាចបង្កគ្រោះថ្នាក់ដល់ថ្លើមដែលរលាក។ បើចាំបាច់ សូមប្រើថ្នាំ Ibuprofen ឬ aspirin ជំនួសវិញ។ មានព័ត៌មានបន្ថែមអំពីការថែទាំថ្លើមដែលមានជំងឺរលាក នៅក្នុងជំពូក ការឈឺពោះ ជំងឺរាក និងព្រូន, ទំព័រ 17 ទៅ 19។

## ការបង្ការ

ត្រូវប្រើស្រោមអនាម័យនៅពេលរួមភេទជានិច្ច ហើយមិនត្រូវប្រើម្ជុលឬឧបករណ៍ផ្សេងទៀត រួមគ្នានៅពេលចាក់ថ្នាំ។ ប្រើទឹកថ្នាំថ្មី ហើយត្រូវប្រាកដថាឧបករណ៍ចាក់សាក់ វះ ចោះ ឬកាត់ស្បែក ត្រូវបានរម្ងាប់មេរោគមុននឹងប្រើ ពីព្រោះមេរោគជំងឺរលាកថ្លើមប្រភេទ C អាចរស់នៅលើផ្ទៃចំហ ឬក្នុងវត្ថុរាវ បានរយៈពេល ៣សប្តាហ៍។ ជំងឺរលាកថ្លើមប្រភេទ C ថែមទាំងអាចឆ្លងតាមរយៈការប្រើច្រាសដុសធ្មេញ ឬឡាមរួមគ្នាទៀតផង។ មិនត្រូវចែកប្រដាប់ប្រដាទាំងនេះជាមួយអ្នកដទៃឡើយ។

វ៉ាក់សាំងដែលការពារជំងឺរលាកថ្លើមប្រភេទ B គឺជាវ៉ាក់សាំងចាក់ ៣ដងជាបន្តបន្ទាប់សម្រាប់ទារក ដែលជាធម្មតាត្រូវបានផ្តល់រួមជាមួយវ៉ាក់សាំងផ្សេងៗទៀតក្នុងអំឡុង ៦ខែដំបូងនៃជីវិត។ ប្រសិនបើម្តាយបានទទួលវ៉ាក់សាំងកន្លងមក ទារកនឹងមិនឆ្លងមេរោគនេះក្នុងអំឡុងពេលកើតនោះទេ។ កុមារធំ និងមនុស្សពេញវ័យដែលមិនបានទទួលវ៉ាក់សាំងកាលពីនៅជាទារកទេ នៅតែអាចទទួលវ៉ាក់សាំងបានដែរ។

# មេរោគអេដស៍

មេរោគអេដស៍ (HIV: Human Immunodeficiency Virus) គឺជាជំងឺកាមរោគដែលឆ្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតតាមរយៈការរួមភេទ តាមរយៈម្ជុលមិនស្អាត និងតាមរយៈការប៉ះពាល់ឈាមដែលមានមេរោគ។ មេរោគអេដស៍មិនឆ្លងតាមរយៈការប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃ ដូចជាការចាប់ដៃ ឱប ឬថើប, តាមរយៈការរស់នៅ លេង, ឬតាមការបរិភោគអាហារជាមួយគ្នា, ឬតាមការដេកក្បែរគ្នានោះទេ។ ម្យ៉ាងទៀត វាមិនឆ្លងតាមអាហារ ទឹក សត្វល្អិត កៅអីបង្គន់ ឬកែវផងដែរ។ ទោះបីជាមនុស្សមួយចំនួនគិតថា មេរោគអេដស៍ និងជំងឺអេដស៍ គឺដូចគ្នាក៏ដោយ ប៉ុន្តែជំងឺអេដស៍គឺជាជំងឺដែលវិវឌ្ឍន៍នៅពេលចុងក្រោយ គឺបន្ទាប់ពីមនុស្សម្នាក់បានឆ្លងមេរោគអេដស៍ មួយរយៈពេលដោយមិនបានទទួលការព្យាបាល។

មេរោគអេដស៍មិនមានរោគសញ្ញាណាមួយទេនៅពេលដំបូង។ មនុស្សដែលមើលទៅហាក់ដូចជាមានសុខភាពល្អទាំងស្រុងក៏ដោយ ក៏អាចនឹងមានមេរោគអេដស៍ ហើយអាចចម្លងវាបានដែរ។ វាអាចនឹងមានពេលរាប់ឆ្នាំ ទើបរោគសញ្ញាដំបូងនៃជំងឺនេះ លេចឡើង។ មធ្យោបាយតែមួយគត់ដើម្បីប្រាកដថាតើអ្នកមានផ្ទុកមេរោគអេដស៍ឬអត់ គឺត្រូវធ្វើតេស្តមេរោគអេដស៍។ ការធ្វើតេស្ត អាចរកបាននៅមណ្ឌលសុខភាពជាច្រើន ក្នុងតម្លៃទាប ឬឥតគិតថ្លៃតែម្តង។

ការព្យាបាលមេរោគអេដស៍/ជំងឺអេដស៍ (ដោយឱសថប្រឆាំងនឹងមេរោគអេដស៍) ឥឡូវនេះមានផ្តល់ជូននៅជាច្រើនកន្លែង ហើយមានផលប៉ះពាល់តិចតួចផងដែរ។ ទោះបីជាវាមិនអាចព្យាបាលឲ្យជាសះស្បើយក៏ដោយ អ្នកដែលប្រើថ្នាំមេរោគអេដស៍ នឹងមិនវិវឌ្ឍន៍ទៅជាជំងឺអេដស៍ឡើយ ប៉ុន្តែនឹងនៅតែមានសុខភាពល្អ ហើយអាចរស់នៅជាធម្មតា និងមានអាយុវែង។ ថ្នាំនេះកំហិតមេរោគនៅក្នុងខ្លួន ដូច្នេះវាជួយបង្ការមិនឲ្យមេរោគអេដស៍ឆ្លងទៅអ្នកដទៃផងដែរ។

ប្រសិនបើអ្នកគិតថាអ្នកអាចនឹងមានមេរោគអេដស៍ សូមធ្វើតេស្តដើម្បីឲ្យអ្នកអាចចាប់ផ្តើមការព្យាបាលយ៉ាងឆាប់បំផុត។ សម្រាប់ព័ត៌មានបន្ថែមអំពីមេរោគអេដស៍ សូមមើលជំពូក មេរោគអេដស៍ និងជំងឺអេដស៍ (កំពុងសរសេរ)។




ការបញ្ចប់នៃមេរោគអេដស៍ នឹងកើតមានឡើង នៅពេលដែលអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ ត្រូវបានព្យាបាលដូចគ្នា ហើយ ថ្នាំមេរោគអេដស៍ អាចរកបានសម្រាប់មនុស្សគ្រប់គ្នា។

# វិធីធ្វើឱ្យមានអារម្មណ៍ធូរស្រាល នៅពេលកំពុងសះស្បើយពីជំងឺកាមរោគ

កាលណាអ្នកកាន់តែឆាប់ចាប់ផ្តើមការព្យាបាលជំងឺកាមរោគ អ្នកកាន់តែឆាប់មានអារម្មណ៍ធូរស្រាល។ លេបថ្នាំទាំងអស់ដែលអ្នកទទួលបាន បើទោះជាអ្នកចាប់ផ្តើមមានអារម្មណ៍ធូរស្រាលនៅមុនពេលអស់ថ្នាំក៏ដោយ។ ដើម្បីទទួលបានភាពធូរស្រាលក្នុងខ្លួនពីជំងឺកាមរោគ មុនពេលដែលជាសះស្បើយ៖



ប្រសិនបើអ្នកមានដំបៅឬមាស់លើប្រដាប់ភេទ ចូរអង្គុយក្នុងចានដែកដែលមានទឹកស្អាតក្តៅឧណ្ហៗ រយៈពេល ១៥នាទី ចំនួន ២ឬច្រើនដងក្នុងមួយថ្ងៃ។ ប្រសិនបើអ្នកមានការបង្ករោគដោយមេរោគផ្សិត អ្នកអាចបន្ថែមទឹកក្រូចឆ្មារបន្តិច ទឹកខ្មេះ យ៉ាអ៊ូ(ដែលគ្មានជាតិផ្អែម) ឬទឹកដោះគោជូរ ទៅក្នុងទឹកក្តៅឧណ្ហៗ។

ប្រសិនបើអ្នកមានពងបែកឈឺចាប់នៅប្រដាប់ភេទ ឬដំបៅលើប្រដាប់ភេទ ចូរសាកល្បងការព្យាបាលទាំងនេះណាមួយ៖



- រុំដុំទឹកកកនៅក្នុងក្រណាត់ស្អាត។ ដាក់វាពីលើដំបៅរយៈពេល ២០នាទីភ្លាមៗនៅពេលអ្នកមានអារម្មណ៍ថាដំបៅកំពុងកើតឡើង។
- ធ្វើស្បៃដោយត្រាំក្រណាត់នៅក្នុងតែខ្មៅត្រជាក់ រួចដាក់វាពីលើដំបៅ។ ស្បៃដែលធ្វើពីសូលុយស្យុង aluminum acetate ក៏អាចបន្ថយភាពឈឺចាប់ផងដែរ។
- អង្គុយនៅក្នុងចានដែកដែលមានទឹកស្អាតត្រជាក់។
- លាយទឹកជាមួយម្សៅសូដា ឬម្សៅពោត ឲ្យទៅជាម្សៅស្អិត រួចលាបពីលើដំបៅ។

ប្រសិនបើអ្នកមានដំបៅប្រដាប់ភេទ ហើយឈឺចាប់នៅពេលនោម ចូរចាក់ទឹកស្អាតនៅលើប្រដាប់ភេទរបស់អ្នក ក្នុងពេលកំពុងនោម។ ឬអង្គុយក្នុងចានទឹកត្រជាក់ ក្នុងពេលដែលអ្នកនោម។

ប្រសិនបើអ្នកឈឺចាប់ សូមប្រើថ្នាំបំបាត់ការឈឺចាប់ ដូចជាថ្នាំ aspirin, ibuprofen ឬ paracetamol (acetaminophen) ។



ស្លៀកពាក់ខោអាវក្នុង ឬខោទ្រនាប់ រលុងៗ។ វាអាចឱ្យខ្យល់ចូលជុំវិញប្រដាប់ភេទ ដែលជួយអ្នកក្នុងការសះស្បើយ។

បោកគក់ខោអាវក្នុងរៀងរាល់ថ្ងៃ រួចហាលថ្ងៃឲ្យស្ងួត។ បែបនេះនឹងសម្លាប់មេរោគដែលអាចបង្កជំងឺ។

មិនត្រូវរួមភេទទេ រហូតទាល់តែអ្នកមានអារម្មណ៍ធូរស្រាល។ ប្រសិនបើអ្នកត្រូវតែរួមភេទ ចូរប្រើស្រោមអនាម័យជាមួយនឹងទឹករំអិល។

# ការមានផ្ទៃពោះ និងជំងឺកាមរោគ



នៅពេលដែលស្ត្រីមានផ្ទៃពោះ មានជំងឺកាមរោគ ទារករបស់គាត់អាចប្រឈមនឹងជំងឺតាមរយៈឈាមម្តាយក្នុងអំឡុងពេលមានផ្ទៃពោះ, អំឡុងពេលកើត, នៅពេលពួកគេឆ្លងកាត់តាមទ្វារមាស, ឬនៅក្នុងទឹកដោះ។

ជំងឺកាមរោគដែលមិនបានព្យាបាល ឬមិនអាចគ្រប់គ្រងបាន អាចប៉ះពាល់ទាំងស្ត្រី និងទារក។ ទារកអាចនឹងកើតមិនគ្រប់ខែ ឬកើតមកមានមាឌតូចខ្លាំង ហើយអាចកើតមកមានជំងឺ ឬឈឺនៅពេលក្រោយ។ ការធ្វើតេស្តជំងឺកាមរោគ អាចឱ្យអ្នកដឹងច្បាស់ថា គ្មានអ្វីដែលគួរព្រួយបារម្ភ ឬវានឹងជួយឲ្យអ្នកទទួលបានការព្យាបាលដ៏ត្រឹមត្រូវក្នុងអំឡុងពេលមានផ្ទៃពោះ ឬពេលសម្រាល។ ការព្យាបាលអាចឲ្យម្តាយ និងកូនជាសះស្បើយ ហើយព្យាបាលប្តីរបស់ស្ត្រីផងដែរ។

## ជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា

ជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា អាចឆ្លងទៅទារកក្នុងអំឡុងពេលសម្រាល ហើយអាចបណ្តាលឱ្យមានជំងឺភ្នែក, ងងឹតភ្នែក ឬបញ្ហាសួតធ្ងន់ធ្ងរ។ ដើម្បីបង្ការជំងឺភ្នែក និងងងឹតភ្នែក ត្រូវដាក់ក្រមួនភ្នែក erythromycin ក្នុងភ្នែករបស់ទារកភ្លាមៗបន្ទាប់ពីកើត (សូមមើលជំពូក ទារកទើបនឹងកើត និងការបំបៅដោះកូន, ទំព័រ 27).

## ជំងឺស្វាយ

ជំងឺស្វាយអាចឆ្លងទៅទារកនៅក្នុងស្បូន ហើយធ្វើឱ្យទារកកើតមិនគ្រប់ខែ មានពិការភាព ឬស្លាប់។ ត្រូវធ្វើតេស្តនិងព្យាបាលក្នុងអំឡុងពេលមានផ្ទៃពោះ។

## ជំងឺពងបែកនៅប្រដាប់ភេទ

ជំងឺពងបែកនៅប្រដាប់ភេទ អាចឆ្លងទៅទារកក្នុងអំឡុងពេលកើត ប្រសិនបើម្តាយមានដំនៅលើប្រដាប់ភេទ។ ប្រសិនបើអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យថ្មីៗថាមានជំងឺពងបែកលើប្រដាប់ភេទ ឬមានដំបៅ ល្អបំផុតគួរសម្រាលកូននៅមន្ទីរពេទ្យ។ ពួកគេអាចនឹងបង្កើតទារកដោយវះកាត់ រួចព្យាបាលទារកបន្ទាប់ពីសម្រាលរួច។

## ជំងឺសិរមាន់




ជាធម្មតា ជំងឺសិរមាន់មិនឆ្លងទៅទារកទេ ប៉ុន្តែវាអាចរំខានដល់អ្នកក្នុងអំឡុងពេលមានផ្ទៃពោះ។ ព្យាបាលជំងឺសិរមាន់ (មើលទំព័រ 40 និង 41) ឬរង់ចាំសម្រាលកូនរួចទើបព្យាបាល។ ដោយសារសិរមាន់អាចហូរឈាមក្នុងពេលសម្រាលកូន សូមពិគ្រោះជាមួយបុគ្គលិកសុខាភិបាលអំពីជម្រើសរបស់អ្នកអំពីការសម្រាលកូននៅក្នុងមន្ទីរពេទ្យ។

### ជំងឺរលាកថ្លើមប្រភេទ B
ស្ត្រីមានផ្ទៃពោះ អាចចម្លងជំងឺរលាកថ្លើមប្រភេទ B ទៅទារក។ ទារកនឹងត្រូវការវ៉ាក់សាំង HepB ភ្លាម បន្ទាប់ពីកើត និងការព្យាបាលផ្សេងៗទៀតដើម្បីបង្ការជំងឺរលាកថ្លើមប្រភេទ B ។

### មេរោគអេដស៍
ការធ្វើតេស្តរកមេរោគអេដស៍ក្នុងពេលមានផ្ទៃពោះ មានន័យថាអ្នកអាចទទួលបានថ្នាំសម្រាប់បង្ការកុំឲ្យឆ្លងរោគទៅទារក។ ថ្នាំព្យាបាលមេរោគអេដស៍ នឹងការពារទាំងម្តាយនិងទារក។

# បង្ការជំងឺកាមរោគ

ជំងឺកាមរោគ ត្រូវបានចម្លងពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀតក្នុងអំឡុងពេលរួមភេទ។ វាកើតឡើង នៅពេលដែលមានការប៉ះពាល់ស្បែកនៃ ឬទឹករំអិលនៃទ្វារមាស លិង្គ រន្ធគូថ ឬមាត់។ មនុស្សគ្រប់គ្នាអាច ឆ្លងជំងឺកាមរោគ ប៉ុន្តែជំងឺកាមរោគអាចមិនងាយឆ្លងរាលដាលទេ នៅពេលដែលមនុស្សអនុវត្តការរួមភេទ ប្រកបដោយសុវត្ថិភាពខ្ពស់, ព្យាបាលជំងឺកាមរោគឲ្យជាសះស្បើយ, និងធ្វើការងារដើម្បីផ្លាស់ប្តូរលក្ខខណ្ឌ ដែលបានធ្វើឱ្យជំងឺកាមរោគ ក្លាយទៅជាបញ្ហាដ៏ធ្ងន់ធ្ងរនេះ។

អ្នកកាន់តែងាយឆ្លងជំងឺកាមរោគ ប្រសិនបើ៖

- ដៃគូរបស់អ្នក មានរោគសញ្ញានៃជំងឺកាមរោគ។ គាត់អាចចម្លងជំងឺកាមរោគបានយ៉ាងងាយ មកដល់អ្នក, ឬប្រហែលជាបានឆ្លងរួចទៅហើយ, បើទោះជាអ្នកគ្មានរោគសញ្ញាក៏ដោយ។
- អ្នកមានដៃគូរួមភេទច្រើនជាងម្នាក់។
- អ្នកមានដៃគូថ្មីដែលប្រហែលជាបានឆ្លងជំងឺកាមរោគពីដៃគូមុនរបស់គាត់។
- ដៃគូរបស់អ្នក មានដៃគូផ្សេងទៀតដែលប្រហែលជាមានជំងឺកាមរោគ។
- អ្នកនិងដៃគូរបស់អ្នក មិនប្រើស្រោមអនាម័យ។
- អ្នករួមភេទជាមួយនរណាម្នាក់ដែលប្រើម្ជុលចាក់រួមគ្នា, ឬបើអ្នកប្រើម្ជុលចាក់ជាមួយគាត់។

**ចូរធ្វើតេស្តឱ្យបានញឹកញាប់ ប្រសិនបើមានការប្រឈមនឹងការឆ្លងជំងឺកាមរោគ។** ការធ្វើតេស្តរកជំងឺកាមរោគ រៀងរាល់ ៦ ទៅ ១២ខែម្តង គឺជាគំនិតល្អសម្រាប់ស្ត្រីនិងបុរសដែលមានការរួមភេទដោយគ្មានការ ការពារ, ជាមួយដៃគូច្រើន, ជាមួយដៃគូដែលរួមភេទជាមួយអ្នកដទៃទៀត, ឬដោយសារមនុស្សម្នាក់ទៀត ចាក់ថ្នាំញៀន។

# ស្ត្រីប្រឈមនឹងហានិភ័យច្រើន

ស្ត្រីប្រឈមនឹងឧបសគ្គជាច្រើនក្នុងការការពារខ្លួនពីជំងឺកាមរោគ និងការទទួលបានការព្យាបាលឱ្យបានគ្រប់គ្រាន់ ជាពិសេសនៅក្នុងសហគមន៍ដែលៈ

- អាពាហ៍ពិពាហ៍កុមារ គឺជារឿងធម្មតា។
- ស្ត្រីត្រូវបានបដិសេធនូវសេវានិងព័ត៌មានអំពីសុខភាពផ្លូវភេទ។
- បុរសត្រូវបានរំពឹងថាមានដៃគូច្រើន។
- ការអប់រំត្រូវបានបដិសេធចំពោះក្មេងស្រីនិងស្ត្រី។
- គ្មាននរណាម្នាក់និយាយអំពីការរំលោភបំពានផ្លូវភេទ ឬពីវិធីបញ្ឈប់វា។
- ស្ត្រីស្ថិតនៅក្នុងស្ថានភាពដែលពិបាកឬមានគ្រោះថ្នាក់ក្នុងការបដិសេធការរួមភេទ។
- ការរកស៊ីផ្លូវភេទ គឺជាបទឧក្រិដ្ឋ។
- ការរួមភេទ និងចំណង់ផ្លូវភេទ ត្រូវបានចាត់ទុកថាគួរឱ្យអាម៉ាស់ ទោះបីវាជារឿងធម្មតាក៏ដោយ ហើយគ្មាននរណានិយាយដោយបើកចំហអំពីបញ្ហាផ្លូវភេទ។





# ការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់

អ្វីទៅជាការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់ ហើយតើអ្នកអាចធ្វើឲ្យការរួមភេទរបស់អ្នក កាន់តែមានសុវត្ថិភាព តាមរបៀបណា? វាប្រហែលជាមិនងាយស្រួលទេ ប៉ុន្តែជាញឹកញាប់អ្នកអាចធ្វើអ្វីមួយបាន។ ការអនុវត្តការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់ អាចបង្ការអ្នកពីការឆ្លងឬចម្លងជំងឺកាមរោគ។


ការថើបមានសុវត្ថិភាព


ការស្ទាបអង្អែល មានសុវត្ថិភាព

នេះគឺជាមធ្យោបាយមួយចំនួនដើម្បីទទួលបានការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់៖

- **កុំរួមភេទ។ ឬហៅថា ការជៀសវាង។** ប្រសិនបើអ្នកមិនរួមភេទ អ្នកនឹងមិនមានជំងឺកាមរោគទេ។ មនុស្សគ្រប់គ្នាអាចធ្វើបែបនេះ ក្នុងរយៈពេលខ្លី ប៉ុន្តែសម្រាប់មនុស្សភាគច្រើន ជម្រើសបែបនេះមិនមែនជាអ្វីដែលពួកគេចង់បានពេញមួយជីវិតនោះទេ។
- **រួមភេទជាមួយដៃគូតែម្នាក់។** ត្រូវប្រាកដថា គាត់រួមភេទជាមួយអ្នកតែម្នាក់ប៉ុណ្ណោះ។ ធ្វើតេស្តរួមគ្នាដើម្បីប្រាកដថាអ្នកទាំងពីរមិនមានជំងឺកាមរោគពីមុនមកទេ។ ភាពស្មោះត្រង់ចំពោះគ្នាទៅវិញទៅមក និងការជៀសវាងការឆ្លងជំងឺកាមរោគតាមរបៀបផ្សេងៗទៀត នឹងការពារអ្នកទាំងពីរ។
- **កុំរួមភេទជាមួយអ្នកដែលមានរោគសញ្ញាជំងឺកាមរោគ។** ជួយគាត់ឱ្យធ្វើតេស្ត និងព្យាបាល មុននឹងអ្នករួមភេទជាមួយគាត់។ ដរាបណាមនុស្សម្នាក់មិនបានធ្វើតេស្តទេ វាពិបាកណាស់ក្នុងការដឹងថាតើនរណាមានជំងឺកាមរោគ ហើយនរណាមិនមាន។ ជំងឺកាមរោគអាចឆ្លងរាលដាលបាន បើទោះជាអ្នកជំងឺមិនមានរោគសញ្ញាក៏ដោយ។
- **រួមភេទដោយមិនស៊កលិង្គចូលក្នុងទ្វារមាសឬរន្ធគូថ។** មានវិធីជាច្រើនក្នុងការផ្ដល់និងទទួលភាពសុខស្រួល ដោយមិនចាំបាច់ស៊កលិង្គចូល ដូចជាការថើប, ការច្របាច់ ឬម៉ាស្សាផ្នែកផ្សេងៗនៃរាងកាយ, និងការស្ទាបអង្អែលប្រដាប់ភេទទៅវិញទៅមកដោយប្រើដៃឬមាត់។
- **ប្រើស្រោមអនាម័យគ្រប់ពេល។** ពាក់ស្រោមអនាម័យ មុនពេលប្រដាប់ភេទរបស់ដៃគូអ្នក ប៉ះនឹងរបស់អ្នក, រៀងរាល់ពេល សូម្បីតែជាមួយដៃគូយូរអង្វែង។ ស្រោមអនាម័យស្ត្រីការពារបានល្អបំផុតពីជំងឺកាមរោគ ព្រោះវាគ្របដណ្ដប់បានច្រើនលើតំបន់ប្រដាប់ភេទស្ត្រី។ ប្រសិនបើអ្នកចង់មានផ្ទៃពោះ ត្រូវរួមភេទដោយមិនប្រើស្រោមអនាម័យតែក្នុងពេលអាចបង្កកំណើតប៉ុណ្ណោះ។ ប្រើស្រោមអនាម័យបុរសឬស្ត្រី (ឬបន្ទះស្តើងទ្រាប់ធ្មេញ ឬប្លាស្ទិករុំ) ក្នុងពេលរួមភេទតាមមាត់។ ចំពោះឧបករណ៍រួមភេទដែលប្រើរួមគ្នា ក៏ត្រូវប្រើស្រោមអនាម័យផងដែរ។


ការរួមភេទតាមមាត់ មិនសូវមានសុវត្ថិភាពទេ ប៉ុន្តែកាន់តែមានសុវត្ថិភាពជាមួយស្រោមអនាម័យ


ការរួមភេទតាមទ្វារមាស គឺមានគ្រោះថ្នាក់ - ប៉ុន្តែកាន់តែមានសុវត្ថិភាពជាមួយស្រោមអនាម័យ


ការរួមភេទតាមរន្ធគូថ មានគ្រោះថ្នាក់ជាខ្លាំង - ប៉ុន្តែកាន់តែមានសុវត្ថិភាពជាមួយស្រោមអនាម័យ

# និយាយអំពីការរួមភេទជាមួយដៃគូ

មនុស្សភាគច្រើនត្រូវបានបង្រៀនមិនឱ្យនិយាយអំពីបញ្ហាផ្លូវភេទ សូម្បីតែជាមួយមនុស្សដែលពួកគេរួមភេទជាមួយ។ នេះជាការផ្តល់យោបល់មួយចំនួន៖

- **ផ្តោតទៅលើសុវត្ថិភាព។** ប្រសិនបើអ្នកចង់រួមភេទដែលមានសុវត្ថិភាព នោះដៃគូរបស់អ្នកប្រហែលជាគិតថាអ្នកមិនទុកចិត្តគាត់។ ប៉ុន្តែចំណុចសំខាន់គឺសុវត្ថិភាព មិនមែនការទុកចិត្តនោះទេ ព្រោះមនុស្សម្នាក់អាចមានជំងឺកាមរោគដោយមិនដឹងខ្លួន។ ការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់ គឺជាគំនិតល្អសម្រាប់ដៃគូទាំងពីរ បើទោះជាអ្នកទាំងពីរមិនមានរួមភេទជាមួយអ្នកដទៃក៏ដោយ។
- **ផ្តោតទៅលើការបង្ការកុំឱ្យមានផ្ទៃពោះដែលមិនចង់បាន។** ប្រសិនបើអ្នកមិនចង់បានកូនឥឡូវនេះទេ អ្នកនិងដៃគូរបស់អ្នកអាចនិយាយអំពីរបៀបដែលស្រោមអនាម័យអាចការពារជំងឺកាមរោគ ព្រមទាំងបង្ការកុំឲ្យមានផ្ទៃពោះ។
- **អនុវត្តការនិយាយជាមួយមិត្តភក្តិ។** សុំមិត្តម្នាក់ឱ្យសម្តែងជាដៃគូរបស់អ្នក បន្ទាប់មកអនុវត្តនូវអ្វីដែលអ្នកចង់និយាយ។ គិតថាតើដៃគូរបស់អ្នកនឹងឆ្លើយតបរបៀបណា រួចអនុវត្តតាមចម្លើយនីមួយៗដែលអាចនឹងកើតឡើង។ វាទំនងជាអ្នកទាំងពីរនឹងមានអារម្មណ៍ភ័យខ្លាចក្នុងការនិយាយអំពីបញ្ហាផ្លូវភេទ ដូច្នេះចូរគិតពីវិធីដើម្បីធ្វើឱ្យការសន្ទនាកាន់តែងាយស្រួលសម្រាប់អ្នកទាំងពីរ។
- **កុំរង់ចាំរហូតដល់អ្នករៀបនឹងរួមភេទ ទើបនិយាយពីរឿងនេះ!** ជ្រើសរើសពេលវេលានៅពេលដែលអ្នកទាំងពីរកំពុងសម្រាក និងមានអារម្មណ៍ល្អចំពោះគ្នា។ ប្រសិនបើអ្នកបានឈប់រួមភេទដោយសារតែអ្នកមានកូនថ្មី ឬកំពុងព្យាបាលដោយជំងឺកាមរោគ ចូរព្យាយាមនិយាយមុនពេលអ្នករួមភេទឡើងវិញ។ ប្រសិនបើអ្នកនិងដៃគូរបស់អ្នករស់នៅឆ្ងាយពីគ្នា ឬត្រូវធ្វើដំណើរឆ្ងាយជាញឹកញាប់ ចូរនិយាយអំពីវិធីការពារសុខភាពផ្លូវភេទ មុនពេលអ្នកជួបគ្នាវិញ។
- **ស្វែងយល់បន្ថែមអំពីហានិភ័យ និងពីរបៀបរួមភេទដែលមានសុវត្ថិភាពខ្ពស់។** អ្នកដែលមិនសូវយល់ដឹងអំពីជំងឺកាមរោគ, របៀបដែលមេរោគឆ្លង, និងផលប៉ះពាល់សុខភាពយូរអង្វែងរបស់វា, មិនអាចយល់ពីគ្រោះថ្នាក់ដែលពាក់ព័ន្ធនឹងការរួមភេទដែលគ្មានសុវត្ថិភាពនោះទេ។ ព័ត៌មានសុខភាព អាចជួយអ្នកក្នុងការបញ្ចុះបញ្ចូលពួកគេអំពីភាពចាំបាច់ក្នុងការអនុវត្តការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់។



# ការព្យាបាលជាបែបបង្ការ

ជំងឺកាមរោគភាគច្រើនអាចនឹងជាសះស្បើយដោយការព្យាបាល ជាពិសេសនៅពេលចាប់ផ្ដើមការព្យាបាលបានឆាប់បំផុត។ ការមានជំងឺកាមរោគមួយ ធ្វើឱ្យមានឱកាសកាន់តែខ្ពស់ក្នុងការឆ្លងមេរោគអេដស៍ឬជំងឺកាមរោគផ្សេងៗទៀត ប៉ុន្តែជាទូទៅបន្ទាប់ពីការព្យាបាល ពួកគេមិនចម្លងជំងឺកាមរោគទៅអ្នកដទៃទេ។

**ព្យាបាលភ្លាមៗ។** បុគ្គលិកសុខាភិបាលស្គាល់ពីសហគមន៍របស់ពួកគាត់ និងថាតើអ្នកដែលមកទទួលជំនួយលើជំងឺកាមរោគ ទំនងជានឹងត្រលប់មកវិញដើម្បីទទួលបានការថែទាំបន្ថែមទៀតដែរឬទេ។ បែបនេះនឹងជួយពួកគាត់ក្នុងការសម្រេចថាតើគួរចាប់ផ្ដើមដោយការព្យាបាលណាមួយ។

**ព្យាបាលទាំងដៃគូផងដែរ។** នៅពេលដែលមនុស្សម្នាក់ដឹងថាគាត់មានជំងឺកាមរោគ នោះអ្នកដទៃទៀតដែលគាត់ធ្លាប់រួមភេទជាមួយ ត្រូវតែធ្វើតេស្ដ៍និងព្យាបាលផងដែរ។ ប្រសិនបើពិបាកក្នុងការនិយាយជាមួយអតីតដៃគូរបស់អ្នក បុគ្គលិកសុខាភិបាលនិងកម្មវិធីព្យាបាលជំងឺកាមរោគ អាចជួយទាក់ទងទៅគាត់ដើម្បីឲ្យបានធ្វើតេស្ដ៍។ ប្រសិនបើអ្នកអាចនិយាយជាមួយអតីតដៃគូដោយសុវត្ថិភាព សូមទទូចឱ្យពួកគេជៀសវាងការរួមភេទទាំងអស់ រហូតបានធ្វើតេស្ដ៍ ព្យាបាល និងជាសះស្បើយពីជំងឺ។

**ការព្យាបាលស្ត្រីមានផ្ទៃពោះយ៉ាងឆាប់រហ័ស** ជួយបង្ការការចម្លងមេរោគនិងបញ្ហានានាទៅទារក (មើលទំព័រ 20)។

## ថ្នាំបង្ការសម្រាប់ជំងឺកាមរោគមួយចំនួន

ការបង្ការជំងឺក្រោយពេលប្រឈម (Post Exposure Prophylaxis - PEP) គឺជាវិធីមួយក្នុងការប្រើប្រាស់ថ្នាំដែលគេប្រើសម្រាប់ព្យាបាលមេរោគអេដស៍ (ហៅថាការព្យាបាលប្រឆាំងនឹងមេរោគអេដស៍) យកទៅបង្ការមនុស្សម្នាក់មិនឲ្យឆ្លងមេរោគអេដស៍។ នៅពេលដែលមនុស្សម្នាក់ប្រឈមនឹងមេរោគអេដស៍ (ឧទាហរណ៍ដោយសារការរំលោភ ឬដោយការរួមភេទមិនប្រើស្រោមអនាម័យ) ការប្រើថ្នាំព្យាបាលមេរោគអេដស៍ឱ្យបានឆាប់ក្នុងអំឡុង ៣ថ្ងៃ អាចបង្ការមិនឲ្យមានមេរោគអេដស៍។ នៅពេលដែលមនុស្សម្នាក់គ្មានផ្ទុកមេរោគអេដស៍ លេបថ្នាំព្យាបាលមេរោគអេដស៍ រៀងរាល់ថ្ងៃដើម្បីបង្ការមេរោគអេដស៍ នេះត្រូវគេហៅថាការបង្ការជំងឺមុនពេលប្រឈម (Pre-Exposure Prophylaxis - PrEP)។ សម្រាប់ព័ត៌មានបន្ថែម សូមមើលជំពូកមេរោគអេដស៍និងជំងឺអេដស៍ (កំពុងសរសេរ) ។

វ៉ាក់សាំងជំងឺរលាកថ្លើមប្រភេទ B និង Hepatitis B immune globulin (HBIG) យ៉ាងពេញលេញ និងចាប់ផ្ដើមបានឆាប់បំផុតបន្ទាប់ពីការប្រឈម អាចបង្ការការឆ្លងមេរោគរលាកថ្លើមប្រភេទ B ។

## ការពិនិត្យរកជំងឺកាមរោគ ការធ្វើតេស្ដ៍ និងកម្មវិធីព្យាបាលជំងឺ គឺសម្រាប់ផ្ដល់ជូននៅគ្រប់ទីកន្លែង

នៅពេលដែលមណ្ឌលសុខភាពផ្ដល់នូវការធ្វើតេស្ដ៍និងការព្យាបាលជំងឺកាមរោគ ជាផ្នែកមួយនៃសេវាផែនការគ្រួសារ ការពិនិត្យផ្ទៃពោះ និងសេវាសុខភាពផ្សេងៗទៀត នោះការធ្វើតេស្ដ៍និងការព្យាបាលកាន់តែមានភាពទូលំទូលាយសម្រាប់មនុស្សគ្រប់គ្នា។ មនុស្សគ្រប់គ្នា ជាពិសេសមនុស្សវ័យក្មេង ត្រូវការសេវាសុខភាពដែលអាចទៅរកបាន តំលៃសមរម្យ និងមានការគោរព។ គ្លីនិកប្រចាំសាលារៀន ឬព្រឹត្តិការណ៍ពិសេសៗដើម្បីផ្ដល់ការធ្វើតេស្ដ៍និងប្រឹក្សាយោបល់នៅតាមកម្មវិធីពិព័រណ៍សុខភាព រង្គសាល កន្លែងរាំច្រៀង ឬទីណាដែលមនុស្សមិនសូវទទួលសេវាថែទាំសុខភាពទៀងទាត់។ ទីណាក៏ដោយដែលមនុស្សបានទៅដល់រួចហើយ គឺជាកន្លែងដ៏ល្អដើម្បីផ្ដល់ព័ត៌មាននិងសេវាពាក់ព័ន្ធនឹងជំងឺកាមរោគ។

## តើបុគ្គលិកសុខាភិបាលអាចលើកកម្ពស់ការបង្ការនិងថែទាំជំងឺកាមរោគ យ៉ាងដូចម្ដេច

**បង្ហាញថាការនិយាយអំពីផ្លូវភេទ គឺជារឿងធម្មតា។** មនុស្សគ្រប់គ្នាមានការព្រួយបារម្ភ ប្រសិនបើមានអ្វីមួយខុសប្រក្រតីនៅលើប្រដាប់ភេទរបស់ខ្លួន។ ហើយជាញឹកញាប់ ពួកគេមានការភ័យខ្លាចក្នុងការស្វែងរកជំនួយ ជាពិសេសប្រសិនបើបញ្ហាហាក់ដូចជាពាក់ព័ន្ធនឹងការរួមភេទ។ អ្នកអាចបង្ហាញពីការបារម្ភដល់ពួកគេ ក្នុងស្ថានភាពបែបនេះ។ យកចិត្តទុកដាក់ជាមួយពួកគេ នោះពួកគេនឹងមានអារម្មណ៍ធូរស្រាល ហើយមិនខ្មាស់ក្នុងការមកជួបអ្នក។ ឥរិយាបថវិជ្ជមានរបស់អ្នក មិនត្រឹមតែជួយដល់បុគ្គលនោះប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយដល់អ្នកដទៃទៀតដែលមិនហ៊ានស្វែងរកការធ្វើតេស្តឬការព្យាបាលដោយសារតែភ័យខ្លាចការវិនិច្ឆ័យមិនល្អ។

**ព័ត៌មានសុខភាព គឺជាបញ្ហាឯកជន។** នៅពេលមនុស្សម្នាក់មករកអ្នកឲ្យជួយ សូមចាត់ទុកអ្វីៗដែលពួកគេបានប្រាប់អ្នក ជារឿងឯកជន។ បើមិនដូច្នេះទេ ពួកគេប្រហែលជាមិនទៅរកប្រព័ន្ធសុខាភិបាលដើម្បីការព្យាបាលតទៀតទេ។

**ការរិះគន់ មិនព្យាបាលនរណាទេ។** មធ្យោបាយល្អបំផុតក្នុងការជួយ គឺការឆ្លើយសំណួរយ៉ាងស្មោះត្រង់ ព្រមទាំងការធ្វើតេស្តនិងថ្នាំពេទ្យចាំបាច់នានា។ ប្រសិនបើអ្នកមិនអាចព្យាបាលជំងឺកាមរោគទេ សូមជួយគាត់ឲ្យស្វែងរកការថែទាំដែលមានតម្លៃទាប នៅក្បែរនោះ។



**គោរពចំណង់ផ្លូវភេទរបស់មនុស្ស។** សូមចងចាំថា មនុស្សដែលអ្នកជួយ អាចជាមនុស្សស្រឡាញ់ភេទដូចគ្នា ឬអ្នកស្រលាញ់ភេទទាំងពីរ បើទោះជាពួកគាត់មិនបានប្រាប់អ្នកក៏ដោយ។ អ្នកអាចស្វែងរកពាក្យសម្រាប់ដៃគូផ្លូវភេទដែលរាប់បញ្ចូលទាំងបុរសនិងស្ត្រី។ ម្យ៉ាងទៀត ត្រូវស្វាគមន៍ចំពោះមនុស្សប្ដូរភេទ ហើយគោរពនូវអ្វីដែលពួកគេប្រាប់អ្នកថាជាមនុស្សប្រុស មនុស្សស្ត្រី ឬពាក្យណាមួយដែលសម្គាល់ភេទរបស់គាត់។ ក្នុងពេលពិនិត្យប្រដាប់ភេទ មិនត្រូវបង្ហាញពីភាពភ្ញាក់ផ្អើលនោះឡើយ ប្រសិនបើគាត់មិនមានអ្វីដែលអ្នកគិតថាត្រូវនឹងភេទរបស់គាត់។ ចូរផ្ដោតទៅលើការព្យាបាលជំងឺរបស់គាត់ ហើយនិយាយអំពីភេទរបស់គាត់ តែនៅពេលដែលគាត់ចង់និយាយប៉ុណ្ណោះ។ សុខភាពរបស់មនុស្សគ្រប់គ្នា កាន់តែល្អប្រសើរ នៅពេលដែលអ្នកអាចជួយនរណាក៏ដោយដែលមានបញ្ហាសុខភាព។

**ជួយមនុស្សវ័យក្មេង។** ជំងឺកាមរោគគឺជាបញ្ហាធ្ងន់ធ្ងរនិងកំពុងកើនឡើងសម្រាប់មនុស្សវ័យក្មេង ជាពិសេសស្ត្រីវ័យក្មេង។ មនុស្សវ័យក្មេងងាយនឹងនិយាយជាមួយអ្នកដទៃដែលមានអាយុស្របាលគ្នា មានគុណតម្លៃ ផែនការ និងជម្រើសស្រដៀងៗគ្នា។ មានពេលជាច្រើនដែលមនុស្សវ័យក្មេង មិនពឹងផ្អែកទៅលើក្រុមគ្រួសារដើម្បីការគាំទ្រនោះទេ។ អ្នកអាចជួយដល់មនុស្សវ័យក្មេងតាមរយៈការផ្ដល់កន្លែងជួបជុំដែលមានសុវត្ថិភាព, គ្មាននរណាម្នាក់វិនិច្ឆ័យពួកគេ, ហើយដែលពួកគេអាចស្វែងរកព័ត៌មានដ៏ត្រឹមត្រូវអំពីសុខភាពផ្លូវភេទ សេវាសុខភាពផ្លូវភេទ និងកង្វល់ផ្សេងទៀតរបស់ពួកគេ។

មនុស្សគ្រប់រូប តែងមានការរួមភេទ។ ការងាររបស់អ្នកក្នុងនាមជាបុគ្គលិកសុខាភិបាល គឺមិនត្រូវធ្វើការវិនិច្ឆ័យឬធ្វើការសម្រេចចិត្តសម្រាប់ពួកគេទេ ផ្ទុយទៅវិញគឺត្រូវព្យាបាលពួកគេ ព្រមទាំងគាំទ្រពួកគេក្នុងការជ្រើសរើសរបៀបដែលមានសុវត្ថិភាព និងមានសុខភាពល្អសម្រាប់ពួកគេ។

**ដើម្បីធ្វើឱ្យសេវាកាន់តែមានប្រយោជន៍សម្រាប់មនុស្សវ័យក្មេង៖**




- ធ្វើឱ្យសេវាសុខភាពរបស់អ្នកមាននៅកន្លែងដែលយុវវ័យធ្លាប់ទៅរួចហើយ ដូចជាសាលារៀន ផ្សារ និងមជ្ឈមណ្ឌលសហគមន៍។
- កំណត់ម៉ោង "សម្រាប់តែយុវជន" នៅក្នុងគ្លីនិកមួយនៅម៉ោងចុងរសៀល, ល្ងាច ឬចុងសប្តាហ៍។
- ផ្តល់ការអះអាងដល់មនុស្សវ័យក្មេង ថាបុគ្គលិកសុខាភិបាលនឹងព្យាបាលពួកគេដោយការគោរព ហើយនឹងមិនប្រាប់ព័ត៌មានរបស់ពួកគេទៅនរណាទៀតឡើយ។
- បណ្តុះបណ្តាលមនុស្សវ័យក្មេង ឲ្យក្លាយជាអ្នកពិគ្រោះយោបល់សម្រាប់មិត្តភក្តិ។
- ផ្តល់សេវាសុខភាពនិងស្រោមអនាម័យដោយឥតគិតថ្លៃ ឬមានតម្លៃទាបបំផុតតាមដែលអាចធ្វើបាន។



# បញ្ចប់ភាពអាម៉ាស់ និងការមាក់ងាយអំពីជំងឺកាមរោគ




**ចែករំលែកព័ត៌មានអំពីស្រោមអនាម័យ និងរបៀបប្រើវា។** រដ្ឋាភិបាល ឬអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ផ្តល់ស្រោមអនាម័យដោយឥតគិតថ្លៃដល់អ្នកដែលត្រូវការវា។ សូមមើលជំពូក ផែនការគ្រួសារ (ទំព័រ. 8) សម្រាប់ព័ត៌មានបន្ថែមអំពីរបៀបប្រើប្រាស់ស្រោមអនាម័យ បុរសនិងស្ត្រី។

**ធ្វើការជាមួយសហគមន៍របស់អ្នក។** និយាយនិងបង្រៀនអំពីសុខភាពផ្លូវភេទ ។ មនុស្សកាន់តែទប់ស្កាត់ជំងឺកាមរោគនៅពេលដែលពួកគេអាចនិយាយអំពីបញ្ហាផ្លូវភេទដោយបើកចំហ និងអាចទទួលបានព័ត៌មាន សេវាសុខភាព និងស្រោមអនាម័យ ក៏ដូចជាការធ្វើតេស្តនិងការព្យាបាលជំងឺកាមរោគផងដែរ។ សៀវភៅ សកម្មភាពដើម្បីសុខភាពស្ត្រី របស់អង្គការ Hesperian មានផ្តល់ជូននូវសកម្មភាពនិងគំនិតជាច្រើនដើម្បីចាប់ផ្តើមការសន្ទនា និងដោះស្រាយបញ្ហានានទាក់ទងនឹងសុខភាពផ្លូវភេទ។

នៅកន្លែងដែលមនុស្សត្រូវបានបង្រៀនថា ការរួមភេទគួរឱ្យអាម៉ាស់ នោះវាកាន់តែពិបាកក្នុងការស្វែងរកជំនួយអំពីជំងឺកាមរោគ។ ប្រសិនបើមនុស្សដែលស្រឡាញ់ភេទដូចគ្នា ត្រូវបានគេរើសអើង ឬលាក់ពួនពីគេ នោះពួកគាត់នឹងកាន់តែពិបាកក្នុងការនិយាយជាមួយដៃគូអំពីការរួមភេទប្រកបដោយសុវត្ថិភាពខ្ពស់ ការធ្វើតេស្ត ឬការជួបបុគ្គលិកសុខាភិបាល។

ការមាក់ងាយ ឬការរើសអើងទៅលើអ្នករកស៊ីផ្លូវភេទ ឬអ្នកដែលមានវណ្ណៈសង្គមទាប ធ្វើឲ្យកាន់តែពិបាកដល់សហគមន៍ក្នុងការបង្ការជំងឺកាមរោគ។

មណ្ឌលសុខភាពអាចជួយកាត់បន្ថយភាពមាក់ងាយលើការមានជំងឺកាមរោគ តាមរយៈការផ្តល់ការធ្វើតេស្តនិងការព្យាបាល ជាផ្នែកមួយនៃការថែទាំសុខភាពទូទៅ សម្រាប់មនុស្សពេញវ័យនិងមនុស្សវ័យក្មេងទាំងអស់។ ដើម្បីឲ្យមនុស្សមានភាពងាយស្រួលក្នុងការធ្វើតេស្តជំងឺកាមរោគ ពួកគេត្រូវការដឹងថា ពួកគេនឹងមិនត្រូវបានផ្តល់ការគោរព និងភាពឯកជន។

ក្នុងពេលយូរអង្វែងមួយ ជំងឺកាមរោគអាចត្រូវបានបង្ការបានល្អបំផុតតាមរយៈការតស៊ូដើម្បីឱ្យមានភាពស្មើភាពគ្នាលើស្ថានភាពសង្គមនិងសេដ្ឋកិច្ចរបស់មនុស្ស។ នៅពេលដែលមនុស្សវ័យក្មេងមានលទ្ធភាពទទួលបានការអប់រំ និងពីអនាគតរបស់ពួកគេ នោះករណីនៃជំងឺកាមរោគនឹងមានកាន់តែតិច។

# ជំងឺកាមរោគ៖ ថ្នាំពេទ្យ

ជំងឺកាមរោគភាគច្រើនអាចត្រូវបានព្យាបាលយ៉ាងជោគជ័យដោយថ្នាំអង់ទីប៊ីយោទិក។ ថ្នាំប្រឆាំងមេរោគផ្សិត និងថ្នាំបន្ថយភាពឈឺចាប់ ក៏ត្រូវបានប្រើផងដែរ។ ទោះបីជាមិនអាចព្យាបាលសះស្បើយក៏ដោយ ក៏គេអាចគ្រប់គ្រងមេរោគអេដស៍ និងជំងឺពងបែកនៅប្រដាប់ភេទបានដោយប្រើថ្នាំពេទ្យ ហើយវានឹងជួយអ្នកឱ្យមានអារម្មណ៍ប្រសើរ និងនៅរក្សាសុខភាពល្អ។ ដើម្បីស្វែងយល់អំពីថ្នាំសម្រាប់មេរោគអេដស៍ សូមមើលជំពូក មេរោគអេដស៍ និងអេដស៍ (កំពុងសរសេរ)។

ថ្នាំសម្រាប់ជំងឺកាមរោគ មានប្រសិទ្ធភាពលុះត្រាតែអ្នកប្រើថ្នាំទាំងអស់ដែលបានផ្តល់ឲ្យ។ បើទោះជារោគសញ្ញាបាត់ទៅវិញក៏ដោយ អ្នកនឹងមិនជាសះស្បើយទេ លុះត្រាតែថ្នាំទាំងអស់មានពេលវេលាដើម្បីធ្វើការ។ ប្រសិនបើរោគសញ្ញាមិនចាប់ផ្តើមបាត់ក្នុងរយៈពេល ៣ថ្ងៃបន្ទាប់ពីលេបថ្នាំទេ ត្រូវជួបបុគ្គលិកសុខាភិបាល។ ការឈឺចាប់ក្នុងទ្វារមាស ឬការធ្លាក់ស ក៏អាចបណ្តាលមកពីបញ្ហាផ្សេងទៀតដែរ ឬមួយអ្នកប្រហែលជាត្រូវការថ្នាំផ្សេងទៀត។

**ចំណាំ៖** គ្រប់កម្រិតដូសទាំងអស់ គឺសម្រាប់មនុស្សពេញវ័យនិងកុមារដែលមានអាយុលើ ១២ឆ្នាំ។

## ថ្នាំអង់ទីប៊ីយ៉ូទិក

ថ្នាំអង់ទីប៊ីយោទិកប្រយុទ្ធនឹងការបង្ករោគដោយបាក់តេរី។ ថ្នាំអង់ទីប៊ីយោទិកផ្សេងគ្នា ប្រយុទ្ធនឹងបាក់តេរីផ្សេងគ្នាដែរ។ ថ្នាំអង់ទីប៊ីយោទិកដែលមានធាតុគីមីផ្សំដូចគ្នា ត្រូវបានចាត់ទុកថាមកពីអម្បូរតែមួយ។ ជាការសំខាន់ណាស់ដែលត្រូវដឹងពីអម្បូរនៃថ្នាំអង់ទីប៊ីយោទិក ព្រោះ៖

1. ថ្នាំអង់ទីប៊ីយោទិកមកពីអម្បូរតែមួយ ភាគច្រើនអាចព្យាបាលជំងឺដូចគ្នា។ នេះមានន័យថា ជួនកាលអ្នកអាចប្រើថ្នាំផ្សេងគ្នាដែលមកពីអម្បូរតែមួយ។
2. ប្រសិនបើអ្នកមានអាល់ឡែស៊ីជាមួយនឹងថ្នាំអង់ទីប៊ីយោទិកមួយ អ្នកក៏នឹងមានអាល់ឡែស៊ីជាមួយថ្នាំផ្សេងទៀតនៃអម្បូរអង់ទីប៊ីយោទិកមួយនោះ។ នេះមានន័យថា អ្នកមិនត្រឹមតែត្រូវប្រើថ្នាំផ្សេងប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រើថ្នាំមកពីអម្បូរផ្សេងទៅទៀត។

ថ្នាំអង់ទីប៊ីយោទិកត្រូវតែផ្តល់ឱ្យសម្រាប់មួយចប់។ ការបញ្ឈប់មុនពេល បើទោះជាអ្នកមានអារម្មណ៍ធូរស្រាលក៏ដោយ អាចធ្វើឱ្យមេរោគត្រលប់មកវិញក្នុងទម្រង់មួយដែលកាន់តែពិបាកក្នុងការបញ្ឈប់។ ទោះជាយ៉ាងនេះក៏ដោយ ប្រសិនបើមានផលប៉ះពាល់ធ្ងន់ធ្ងរពីថ្នាំអង់ទីប៊ីយោទិក ដូចជារាករូសញ្ជឹកញាប់ ឬកន្ទួលរមាស់ដែលរាលដាលពេញរាងកាយយ៉ាងឆាប់រហ័ស អ្នកប្រហែលជាត្រូវឈប់ប្រើថ្នាំអង់ទីប៊ីយោទិក។ សម្រាប់ជំនួយក្នុងការសម្រេចចិត្ត សូមជួបបុគ្គលិកសុខាភិបាលជាបន្ទាន់។

# Amoxicillin

Amoxicillin គឺជាអង់ទីប៊ីយ៉ូទិកមកពីអម្បូរ penicillin ដែលត្រូវបានប្រើដើម្បីព្យាបាលជំងឺកាមរោគ និងជំងឺឆ្លងផ្សេងទៀត។ ដោយសារតែមានភាពស៊ាំនឹងថ្នាំ ថ្នាំនេះមិនសូវមានប្រយោជន៍ដូចកាលពីមុនទេ។

## ផលរំខាន

Amoxicillin អាចបណ្ដាលឲ្យរាក មានកន្ទួល ចង្អោរ ឬក្អួត។ វាអាចបណ្ដាលឱ្យមានការបង្ករោគដោយមេរោគផ្សិតទៅលើស្ត្រី ឬមានកន្ទួលលើកុមារ។

## សំខាន់ ⚠

សូមកុំប្រើ ប្រសិនបើមានអាល់ឡែស៊ីទៅនឹងថ្នាំមកពីអម្បូរ penicillin ។

ប្រសិនបើមិនចាប់ផ្ដើមមានភាពធូរស្រាលក្នុងរយៈពេល ៣ថ្ងៃទេ អ្នកប្រហែលជាត្រូវការថ្នាំផ្សេងទៀត។

## របៀបប្រើ

លេបជាមួយអាហារ។

**សម្រាប់ជំងឺប្រមេះទឹកថ្លា៖**

➡ ផ្ដល់ចំនួន 500 mg ជាថ្នាំលេប ៣ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ។ សូមកុំប្រើថ្នាំ amoxicillin ដើម្បីព្យាបាលជំងឺប្រមេះទឹកថ្លា លុះត្រាតែគ្មានទាំងថ្នាំ azithromycin និង doxycycline ។

**សម្រាប់ជំងឺរលាកអាងត្រគាក** (PID)៖

➡ ផ្ដល់ចំនួន 500 mg ជាថ្នាំលេប ៣ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ (ម្យ៉ាងទៀត ផ្ដល់ថ្នាំ ceftriaxone ឬ spectinomycin ដើម្បីព្យាបាលជំងឺរលាកអាងត្រគាក, មើលទំព័រ 43)។ សូមកុំប្រើថ្នាំ amoxicillin ដើម្បីព្យាបាលជំងឺ PID លុះត្រាតែមិនអាចរកថ្នាំទាំងនេះបាន ៖ azithromycin, doxycycline ឬ erythromycin ។

# Azithromycin

Azithromycin គឺជាថ្នាំអង់ទីប៊ីយ៉ូទិកនៃអម្បូរ macrolide ដែលត្រូវបានប្រើសម្រាប់ព្យាបាលជំងឺកាមរោគជាច្រើនប្រភេទ។ វាមានសុវត្ថិភាពក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលបំបៅកូនដោយទឹកដោះម្ដាយ។

## ផលរំខាន

Azithromycin អាចបណ្ដាលឲ្យរាក ចង្អោរ ក្អួត និងឈឺពោះ។

## សំខាន់ ⚠

សូមកុំប្រើថ្នាំអង់ទីប៊ីយោទិកនេះ ប្រសិនបើអ្នកមានអាល់ឡែស៊ីទៅនឹងថ្នាំ erythromycin ឬថ្នាំផ្សេងទៀតក្នុងអម្បូរ macrolide ។

## របៀបប្រើ

**សម្រាប់ជំងឺប្រមេះទឹកបាយ ជំងឺប្រមេះទឹកថ្លា ឬជំងឺធំពៅប្រដាប់ភេទ៖**

➡ ផ្ដល់ចំនួន 1 gram (1000 mg) ជាថ្នាំលេប តែមួយដងប៉ុណ្ណោះ។ (ដើម្បី ព្យាបាលជំងឺប្រមេះទឹកបាយ, សូមផ្ដល់ថ្នាំ ceftriaxone ឬថ្នាំផ្សេងទៀតផងដែរ, មើលទំព័រ 42។)

**សម្រាប់ជំងឺរលាកអាងត្រគាក** (PID)៖

➡ ផ្តល់ចំនួន 1 gram (1000 mg) ជាថ្នាំលេប មួយដូស។ ផ្តល់ដូសទី២ នៅមួយសប្តាហ៍បន្ទាប់។ (ដើម្បីព្យាបាលជំងឺរលាកអាងត្រគាក, សូមផ្តល់ថ្នាំ ceftriaxone ឬ spectinomycin ផងដែរ, មើលទំព័រ 43។)

# Benzathine penicillin

Benzathine penicillin គឺជាថ្នាំអង់ទីប៊ីយោទិកដែលមានសកម្មភាពយូរនៃអម្បូរ penicillin ដែលត្រូវបានប្រើសម្រាប់ព្យាបាលជំងឺស្វាយ និងជំងឺដំបៅប្រដាប់ភេទ។ វាត្រូវបានផ្តល់ជាថ្នាំចាក់ចូលសាច់ដុំ។

## សំខាន់ ⚠

សូមកុំប្រើប្រសិនបើអ្នកមានអាល់ឡែស៊ីទៅនឹងថ្នាំនៃអម្បូរ penicillin ។ ត្រូវមានថ្នាំ epinephrine ជាប់ជានិច្ចនៅពេលដែលអ្នកចាក់ថ្នាំ penicillin ។ សង្កេតមើលប្រតិកម្មអាល់ឡែស៊ី និងស្តុកអាល់ឡែស៊ី ដែលអាចនឹងចាប់ផ្តើមក្នុងរយៈពេល ៣០នាទី។

## របៀបប្រើ 

អាចមានភាពឈឺចាប់ក្នុងពេលចាក់។ ចូរលាយជាមួយថ្នាំ lidocaine 1% ប្រសិនបើអ្នកចេះ។

**សម្រាប់ជំងឺស្វាយ៖**

➡ ប្រសិនបើមានដំបៅ ឬកន្ទួលលើរាងកាយ ឬរោគសញ្ញាផ្សេងទៀតនៃជំងឺស្វាយនៅដំណាក់កាលដំបូង, សូមចាក់ 2,4 លាន Units ទៅក្នុងសាច់ដុំ តែមួយដងប៉ុណ្ណោះ។ អ្នកដែលធ្លាប់មានលទ្ធផលតេស្តបង្ហាញថាគ្មានជំងឺស្វាយ ហើយបន្ទាប់មកការធ្វើតេស្តបង្ហាញថាមានជំងឺស្វាយ ក្នុងពេលតិចជាងមួយឆ្នាំក្រោយ ក៏ត្រូវការថ្នាំនេះផងដែរ។

ប្រសិនបើមនុស្សម្នាក់ទំនងជាមានជំងឺស្វាយជាងមួយឆ្នាំហើយ ឬមានបញ្ហាផ្លូវចិត្ត ឬបញ្ហាដទៃទៀតដែលកើតឡើងបន្ទាប់ពីមានជំងឺស្វាយជាច្រើនឆ្នាំមក ដូច្នេះថ្នាំតែមួយដូស គឺមិនគ្រប់គ្រាន់ទេ។ នៅពេលការធ្វើតេស្តបង្ហាញថាជាជំងឺស្វាយ ហើយប្រហែលជាមានយ៉ាងតិច ២ឆ្នាំមកហើយ ឬយូរជាងនេះ, ត្រូវចាក់ 2,4 លាន Units ទៅក្នុងសាច់ដុំ មួយសប្តាហ៍ម្តង រយៈពេល ៣សប្តាហ៍។ ជួយអ្នកជំងឺឱ្យទទួលបានការធ្វើតេស្តនិងការព្យាបាលត្រឹមត្រូវពីបុគ្គលិកសុខាភិបាលដែលមានបទពិសោធន៍។

# Cefixim

Cefixime គឺជាថ្នាំអង់ទីប៊ីយោទិកមកពីអម្បូរ cephalosporin ដែលត្រូវបានប្រើសម្រាប់ព្យាបាលជំងឺឆ្លងជាច្រើនរួមទាំងជំងឺប្រមេះទឹកបាយ។

## ផលរំខាន 

Cefixime អាចបណ្តាលឲ្យឈឺក្រពះ រាក និងឈឺក្បាល។

## សំខាន់ ⚠

សូមកុំប្រើប្រសិនបើអ្នកអាល់ឡែស៊ីទៅនឹងថ្នាំនៃអម្បូរ cephalosporin ។ ចូរសង្កេតមើលប្រតិកម្មអាល់ឡែស៊ី។ ត្រូវត្រៀមខ្លួនជាស្រេចក្នុងការព្យាបាលប្រតិកម្មនិងស្តុកអាល់ឡែហ្ស៊ី នៅពេលអ្នកចាក់ថ្នាំអង់ទីប៊ីយោទិក។

អ្នកដែលមានបញ្ហាថ្លើម គួរប្រុងប្រយ័ត្ននៅពេលប្រើថ្នាំ cefixime ។

### របៀបប្រើ 

**សម្រាប់ជំងឺប្រមេះទឹកបាយ៖**

➡ ផ្ដល់ចំនួន 400 mg ជាថ្នាំលេប តែមួយដងប៉ុណ្ណោះ (ដើម្បី ព្យាបាលជំងឺប្រមេះទឹកបាយ, ត្រូវផ្ដល់ថ្នាំ azithromycin ឬថ្នាំផ្សេងទៀតផងដែរ, មើលទំព័រ 42។)

## Ceftriaxone

Ceftriaxone គឺជាថ្នាំអង់ទីប៊ីយោទិកនៃអម្បូរ cephalosporin ដែលត្រូវបានចាក់ទៅក្នុងសាច់ដុំ និងសរសៃវ៉ែន។ វាត្រូវបានប្រើសម្រាប់ជំងឺឆ្លងជាច្រើន រួមទាំងជំងឺប្រមេះទឹកបាយ និងជំងឺរលាកអាងត្រគាក (PID)។

### សំខាន់ ⚠

សូមកុំប្រើថ្នាំនេះ ប្រសិនបើអ្នកអាល់ឡែស៊ីទៅនឹងថ្នាំនៃអម្បូរ cephalosporin ។ ចូរសង្កេតមើលប្រតិកម្មអាល់ឡែស៊ី។ ត្រូវត្រៀមខ្លួនជាស្រេចក្នុងការព្យាបាលប្រតិកម្មនិងស្ហុកអាល់ឡែហ្ស៊ី នៅពេលអ្នកចាក់ថ្នាំអង់ទីប៊ីយោទិក។

### របៀបប្រើ 

អាចមានភាពឈឺចាប់ក្នុងពេលចាក់។ ចូរលាយជាមួយថ្នាំ lidocaine 1% ប្រសិនបើអ្នកចេះ។

**សម្រាប់ជំងឺប្រមេះទឹកបាយ លើមនុស្សពេញវ័យ៖**

➡ ចាក់ចំនួន 250 mg ទៅក្នុងសាច់ដុំ តែមួយដងប៉ុណ្ណោះ។ (ដើម្បីព្យាបាលជំងឺប្រមេះទឹកបាយ ត្រូវផ្ដល់ថ្នាំ azithromycin ឬថ្នាំផ្សេងទៀតផងដែរ, មើលទំព័រ 42។)

**សម្រាប់ជំងឺរលាកអាងត្រគាក** (PID)៖

➡ ចាក់ចំនួន 250 mg ទៅក្នុងសាច់ដុំ តែមួយដងប៉ុណ្ណោះ។ (ដើម្បីព្យាបាលជំងឺរលាកអាងត្រគាក ត្រូវផ្ដល់ថ្នាំ doxycycline ឬថ្នាំផ្សេងទៀតផងដែរ, មើលទំព័រ 43។)

**សម្រាប់ជំងឺដំបៅប្រដាប់ភេទ៖**

➡ ចាក់ចំនួន 250 mg ទៅក្នុងសាច់ដុំ តែមួយដងប៉ុណ្ណោះ

## Ciprofloxacin

Ciprofloxacin គឺជាថ្នាំអង់ទីប៊ីយោទិកនៃអម្បូរ quinolone ដែលត្រូវបានប្រើសម្រាប់ជំងឺផ្សេងៗ រួមទាំងជំងឺដំបៅប្រដាប់ភេទ។

### ផលរំខាន 

Ciprofloxacin អាចបណ្ដាលឲ្យចង្អោរ រាក ក្អួត ឬឈឺក្បាល។

### សំខាន់ ⚠
សូមកុំប្រើថ្នាំនេះ ប្រសិនបើអ្នកមានផ្ទៃពោះ កំពុងបំបៅដោះកូន ឬមានអាយុក្រោម ១៦ឆ្នាំ។

កុំប្រើជាមួយផលិតផលទឹកដោះគោ។

### របៀបប្រើ
សូមផឹកទឹកមួយកែវ បន្ទាប់ពីប្រើថ្នាំនេះរួច។

**សម្រាប់ជំងឺធំបៅប្រផាប់ភេទ៖**

➡ ផ្តល់ចំនួន 500 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៣ថ្ងៃ។ ផ្តល់រយៈពេល ៧ថ្ងៃ ប្រសិនបើគាត់មានមេរោគអេដស៍ផងដែរ។

## Clindamycin

Clindamycin គឺជាថ្នាំអង់ទីប៊ីយោទិកប្រើសម្រាប់ជំងឺផ្សេងៗ រួមទាំងជំងឺរលាកទ្វារមាសដោយបាក់តេរី។

### ផលរំខាន
ចង្អោរ ក្អួត និងរាក អាចកើតមានក្នុងអំឡុងពីរបីសប្តាហ៍ដំបូងនៃការប្រើថ្នាំ clindamycin ។ ប្រសិនបើអ្នកមានកន្ទួលលើស្បែក ត្រូវឈប់ប្រើវា រួចជួបបុគ្គលិកសុខាភិបាល។

### សំខាន់ ⚠
ប្រសិនបើអ្នកកំពុងបំបៅដោះកូន ហើយថ្នាំនេះធ្វើឲ្យកូនរបស់អ្នក រាក ត្រូវឈប់ប្រើវា។

ការប្រើច្រើនជាង ៣០ថ្ងៃ អាចបណ្តាលឲ្យមានជ្រាំង និងការបង្ករោគដោយមេរោគផ្សិត និងគ្រោះថ្នាក់ចំពោះអ្នកដែលមានបញ្ហាតម្រងនោមនិងថ្លើម។ ថ្នាំក្រែមប្រើក្នុងទ្វារមាស អាចធ្វើឲ្យស្រោមអនាម័យចុះខ្សោយរយៈពេលដល់ ៣ថ្ងៃ បន្ទាប់ពីប្រើ។

### របៀបប្រើ
វាមានជាថ្នាំគ្រាប់សម្រាប់លេប និងជាថ្នាំក្រែម។

**សម្រាប់ជំងឺរលាកទ្វារមាសដោយបាក់តេរី៖**

➡ ផ្តល់ចំនួន 300 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ ឬ ដាក់បញ្ចូលចំនួន 5 g នៃថ្នាំក្រែម 2% (ពេញ ១ប្រដាប់សិកបញ្ចូល) យ៉ាងជ្រៅទៅក្នុងទ្វារមាស រៀងរាល់យប់ រយៈពេល ៧យប់

## Doxycycline

Doxycycline គឺជាថ្នាំអង់ទីប៊ីយោទិកនៃអម្បូរ tetracycline ដែលប្រើសម្រាប់ព្យាបាលជំងឺកាមរោគជាច្រើនប្រភេទ។ វាអាចត្រូវបានប្រើជំនួសថ្នាំ tetracycline ហើយងាយស្រួលប្រើ ព្រោះវាត្រូវលេបតិចដងក្នុងមួយថ្ងៃ។

### ផលរំខាន
Doxycycline អាចបណ្តាលឲ្យរាក ឬឈឺក្រពះ។ មនុស្សខ្លះមានកន្ទួលរមាស់ បន្ទាប់ពីត្រូវកម្តៅថ្ងៃយ៉ាងយូរ។

### សំខាន់ ⚠

សូមកុំប្រើប្រសិនបើអាល់ឡែស៊ីនឹងថ្នាំអង់ទីប៊ីយោទិកនៃអម្បូរ tetracycline ។

សូមកុំប្រើថ្នាំ doxycycline ប្រសិនបើមានផ្ទៃពោះ ហើយព្យាយាមចៀសវាងប្រសិនបើកំពុងបំបៅដោះកូន។

### របៀបប្រើ

ចៀសវាងទឹកដោះគោ ថ្នាំជាតិដែក និងថ្នាំបន្សាបជាតិអាស៊ីដ រយៈពេល ២ម៉ោងមុនឬក្រោយលេបថ្នាំ។ សូមកុំប្រើថ្នាំ ភ្លាមៗនៅមុនពេលសម្រាក។ ក្រោកអង្គុយនៅពេលលេបថ្នាំ ហើយផឹកទឹកឲ្យបានច្រើនដើម្បីបង្ការការរលាកដែលបណ្ដាលមកពីការលេបថ្នាំនេះ។

**សម្រាប់ជំងឺប្រមេះទឹកបាយ ឬជំងឺប្រមេះទឹកថ្លា៖**

➡ ផ្ដល់ចំនួន 100 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ (វានឹងព្យាបាលជំងឺប្រមេះទឹកថ្លា ប៉ុន្តែក៏ព្យាបាលជំងឺប្រមេះទឹកបាយផងដែរ, ត្រូវការប្រើថ្នាំបន្ថែមមួយទៀត, មើលទំព័រ 42។)

**សម្រាប់ជំងឺស្វាយធំចុងៗ៖**

➡ ផ្ដល់ចំនួន 100 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ។ ជាការប្រសើរគួរប្រើថ្នាំ benzathine penicillin សម្រាប់ជំងឺស្វាយទេ លុះត្រាតែគ្មានថ្នាំ ឬអ្នកជំងឺអាល់ឡែស៊ីនឹងថ្នាំ penicillin ។

**សម្រាប់ជំងឺរលាកអាងត្រគាក (PID)៖**

➡ ផ្ដល់ចំនួន 100 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ, រយៈពេល ១៤ថ្ងៃ។ (ដើម្បីជំងឺរលាកអាងត្រគាក ត្រូវផ្ដល់ថ្នាំ ceftriaxone ឬ spectinomycin ផងដែរ, មើលទំព័រ 43។)

## Erythromycin

Erythromycin គឺជាថ្នាំអង់ទីប៊ីយូទិកក្នុងអម្បូរ macrolide ដែលប្រើសម្រាប់ព្យាបាលការបង្ករោគជាច្រើន រួមទាំងជំងឺកាមរោគមួយចំនួន។ វាមានសុវត្ថិភាពក្នុងការប្រើចំពោះស្ត្រីមានផ្ទៃពោះ និងអាចរកបានច្រើនកន្លែង, ប៉ុន្តែសម្រាប់ជំងឺកាមរោគភាគច្រើន វាលែងមានប្រសិទ្ធភាពដូចថ្នាំអង់ទីប៊ីយោទិកដទៃទៀតហើយ។

### ផលរំខាន

Erythromycin អាចបណ្ដាលឲ្យឈឺក្រពះ ឬធ្វើឲ្យចង្អោរ ក្អួត និងរាក។

### សំខាន់ ⚠

សូមកុំប្រើប្រសិនបើអ្នកអាល់ឡែស៊ីនឹងថ្នាំអង់ទីប៊ីយោទិកក្នុងអម្បូរ macrolide ។

### របៀបប្រើ

Erythromycin មានប្រសិទ្ធភាពបំផុតនៅពេលដែលលេប ១ម៉ោងមុន ឬ ២ម៉ោងក្រោយហូបអាហារ។ ប្រសិនបើលេបបែបនេះ ធ្វើទុក្ខក្រពះខ្លាំងពេក ចូរលេបជាមួយអាហារបន្តិច។ មិនត្រូវបំបែកគ្រាប់ថ្នាំទេ ព្រោះវាត្រូវបានរុំស្រោបដើម្បីការពារពីទឹកអាស៊ីដក្រពះ មុននឹងវាអាចចាប់ផ្ដើមធ្វើការនៅក្នុងពោះវៀន។

**សម្រាប់ជំងឺប្រមេះទឹកថ្លា៖**

➡ ផ្ដល់ចំនួន 500 mg ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

**សម្រាប់ជំងឺធំពៅប្រដាប់ភេទ៖**

➡ ផ្តល់ចំនួន 500 mg ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

**សម្រាប់ជំងឺស្វាយ៖**

➡ ផ្តល់ចំនួន 500 mg ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ១៥ថ្ងៃ។ ជាការប្រសើរគួរប្រើថ្នាំ benzathine penicillin សម្រាប់ជំងឺស្វាយទេ លុះត្រាតែមិនអាចរកបាន ឬអ្នកជំងឺអាល់ឡែស៊ីនឹងថ្នាំ penicillin ។ ឬ, បើមាន, ថ្នាំ doxycycline នឹងមានប្រសិទ្ធភាពជាងថ្នាំ erythromycin សម្រាប់ជំងឺស្វាយ។

**សម្រាប់ជំងឺរលាកអាងត្រគាក** (PID)៖

➡ ផ្តល់ចំនួន 500 mg ជាថ្នាំលេប ៤ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ។ (ដើម្បីព្យាបាល ជំងឺរលាកអាងត្រគាក ត្រូវផ្តល់ថ្នាំ ceftriaxone ឬ spectinomycin ផងដែរ, មើលទំព័រ 43។)

# Metronidazole

Metronidazole គឺជាថ្នាំអង់ទីប៊ីយោទិកប្រើសម្រាប់ព្យាបាលការបង្ករោគនៅទ្វារមាសដែលបណ្តាលមកពីជំងឺរលាកទ្វារមាសដោយបាក់តេរី (BV), ជំងឺទ្រីកូម៉ូណាស់, ឬជំងឺរលាកអាងត្រគាក។

## ផលរំខាន

Metronidazole អាចបណ្តាលឲ្យមានរសជាតិដែកនៅក្នុងមាត់ ទឹកនោមពណ៌ចាស់ ឈឺក្រពះ ចង្អោរ និងឈឺក្បាល។

## សំខាន់ ⚠

សូមកុំប្រើថ្នាំនេះប្រសិនបើអ្នកមានជំងឺខាន់លឿង (ភ្នែកលឿង) ឬបញ្ហាផ្សេងៗទៀតពាក់ព័ន្ធនឹងថ្លើម។

ត្រូវឈប់លេបថ្នាំប្រសិនបើអ្នកមានអារម្មណ៍ស្ពឹកៗ។

ក្នុងពេលប្រើថ្នាំ metronidazole មិនត្រូវផឹកស្រាទេ សូម្បីតែ ១កំប៉ុង។ វានឹងធ្វើឲ្យអ្នកមានអារម្មណ៍ចង្អោរយ៉ាងខ្លាំង។

## របៀបប្រើ

វាមានជាថ្នាំស៊កក្នុងទ្វារមាស និងជាថ្នាំលេប។

**សម្រាប់ជំងឺរលាកទ្វារមាសដោយបាក់តេរី ឬជំងឺទ្រីកូម៉ូណាស់៖**

➡ ផ្តល់ចំនួន 2 grams (2000 mg) ជាថ្នាំលេប, តែមួយដងប៉ុណ្ណោះ (មិនណែនាំសម្រាប់ស្ត្រីមានផ្ទៃពោះទេ)
ឬ
ផ្តល់ចំនួន 400 ទៅ 500 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ, រយៈពេល ៧ថ្ងៃ
ឬ
ស៊កមួយគ្រាប់ 500 mg ទៅក្នុងទ្វារមាសយ៉ាងជ្រៅ រៀងរាល់យប់ រយៈពេល ៧យប់

**សម្រាប់ជំងឺរលាកអាងត្រគាក** (PID)៖

➡ ផ្តល់ចំនួន 400 ទៅ 500 mg ជាថ្នាំលេប, ៣ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ។ (ដើម្បីព្យាបាលជំងឺរលាកអាងត្រគាក ត្រូវផ្តល់ថ្នាំ ២មុខផ្សេងទៀតផងដែរ, មើលទំព័រ 43។)

# Spectinomycin

Spectinomycin គឺជាថ្នាំអង់ទីប៊ីយោទិក aminocyclitol ប្រើសម្រាប់ព្យាបាលជំងឺរលាកអាងត្រគាក និងជំងឺប្រមេះទឹកបាយ, ប៉ុន្តែវាគ្មានប្រសិទ្ធភាពចំពោះជំងឺប្រមេះទឹកបាយក្នុងបំពង់កនោះទេ។ វាមានប្រយោជន៍ពិសេសសម្រាប់អ្នកដែលអាល់ឡែស៊ីនឹងពូកថ្នាំអង់ទីប៊ីយោទិក penicillin និង cephalosporin ។

## ផលរំខាន

វាអាចបណ្ដាលឲ្យញ័រញាក់, ឈឺចាប់ឬឡើងក្រហមនៅកន្លែងចាក់, វិលមុខ, និងចង្អោរ។

## របៀបប្រើ

វាមានជាថ្នាំដបសម្រាប់ចាក់ ចំនួន 2 g ។

**សម្រាប់ជំងឺប្រមេះទឹកបាយ ឬជំងឺរលាកអាងត្រគាក** (PID)៖

➡ ចាក់ចំនួន 2 g (2000 mg) ទៅក្នុងសាច់ដុំ, តែមួយដងប៉ុណ្ណោះ។ (ដើម្បីព្យាបាលជំងឺរលាកអាងត្រគាក ត្រូវផ្ដល់ថ្នាំ doxycycline ឬថ្នាំផ្សេងទៀតផងដែរ, មើលទំព័រ 43។)

# Tetracycline

Tetracycline គឺថ្នាំអង់ទីប៊ីយោទិកក្នុងអម្បូរ tetracycline, ប្រើសម្រាប់ព្យាបាលការបង្ករោគជាច្រើន រួមទាំងជំងឺប្រមេះទឹកថ្លា។ Doxycycline មានប្រសិទ្ធភាពសម្រាប់ការបង្ករោគដូចគ្នា អាចតម្លៃទាបជាង និងស្រួលលេបជាង។

## ផលរំខាន

ប្រសិនបើអ្នកស្ថិតក្រោមកម្ដៅថ្ងៃយូរ វាអាចបណ្ដាលឲ្យឡើងកន្ទួលរមាស់។ វាអាចបណ្ដាលឲ្យរាក ឬឈឺក្រពះ។

## សំខាន់ ⚠

សូមកុំលេប ប្រសិនបើអាល់ឡែស៊ីនឹងថ្នាំអង់ទីប៊ីយោទិកក្នុងអម្បូរ tetracycline family ។

សូមកុំប្រើថ្នាំ tetracycline ប្រសិនបើអ្នកមានផ្ទៃពោះ ឬបំបៅដោះកូន។

## របៀបប្រើ

ចៀសវាងទឹកដោះគោ ថ្នាំជាតិដែក និងថ្នាំបន្សាបជាតិអាស៊ីដនៅ ២ម៉ោងមុនឬក្រោយលេបថ្នាំ។

**សម្រាប់ជំងឺប្រមេះទឹកថ្លា៖**

➡ ផ្ដល់ចំនួន 500 mg ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

# Tinidazole

Tinidazole គឺជាថ្នាំអង់ទីប៊ីយោទិក ស្រដៀងនឹង metronidazole ដែរ ហើយប្រើសម្រាប់ព្យាបាលការបង្ករោគនៅទ្វារមាសមួយចំនួន។

## ផលរំខាន

Tinidazole អាចបណ្តាលឲ្យមានរសជាតិដែកនៅក្នុងមាត់ ឈឺក្រពះ ចង្អោរ ឬឈឺក្បាល។

## សំខាន់

សូមកុំប្រើថ្នាំនេះប្រសិនបើមានផ្ទៃពោះ។

មិនត្រូវផឹកស្រាទេ សូម្បីតែ ១កំប៉ុង ក្នុងពេលអ្នកកំពុងប្រើថ្នាំ tinidazole ឬពេល ៣ថ្ងៃបន្ទាប់។ វានឹងធ្វើឲ្យអ្នកមានអារម្មណ៍ចង្អោរយ៉ាងខ្លាំង។

## របៀបប្រើ

ផឹកទឹកមួយកែវ បន្ទាប់ពីប្រើថ្នាំនេះរួច។

**សម្រាប់ជំងឺរលាកទ្វារមាសដោយបាក់តេរី ឬជំងឺទ្រីកូម៉ូណាស់៖**

➡ ផ្តល់ចំនួន 2 grams (2000 mg) ជាថ្នាំលេប, តែមួយដងប៉ុណ្ណោះ។
ឬ
ផ្តល់ចំនួន 500 mg ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ

ចំពោះជំងឺទ្រីកូម៉ូណាស់ ចូរព្យាបាលដៃគូរួមភេទរបស់គាត់ផងដែរ, ប៉ុន្តែវាមិនចាំបាច់ទេចំពោះជំងឺរលាកទ្វារមាសដោយបាក់តេរី។

# ថ្នាំប្រឆាំងនឹងមេរោគផ្សិត

## Clotrimazole

Clotrimazole គឺជាថ្នាំប្រឆាំងនឹងមេរោគផ្សិត ប្រើសម្រាប់ព្យាបាលការបង្ករោគដោយមេរោគផ្សិត នៅក្នុងទ្វារមាស លិង្គ មាត់ និងស្បែក។

### ផលរំខាន 

Clotrimazole អាចធ្វើឲ្យរមាស់ស្បែក។ ឈប់ប្រើវាប្រសិនបើឡើងកន្ទួល។

### របៀបប្រើ 

វាមានជាទម្រង់ថ្នាំសុលសម្រាប់ទ្វារមាស និងជាថ្នាំក្រែម។

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស**

➡ បើប្រើថ្នាំក្រែម 1% ៖ ដាក់បញ្ចូលថ្នាំក្រែមចំនួន 5 g យ៉ាងជ្រៅទៅក្នុងទ្វារមាស រៀងរាល់យប់ រយៈពេល ៧យប់
ឬ
បើប្រើថ្នាំក្រែម 2% ៖ ដាក់បញ្ចូលថ្នាំក្រែមចំនួន 5 g យ៉ាងជ្រៅទៅក្នុងទ្វារមាស រៀងរាល់យប់ រយៈពេល ៣យប់
ឬ
បើប្រើថ្នាំសុល ចូរសុលថ្នាំមួយគ្រាប់យ៉ាងជ្រៅទៅក្នុងទ្វារមាស រៀងរាល់យប់ រួមទាំងពេលមានរដូវ។ ប្រើថ្នាំសុល 100 mg រយៈពេល ៧យប់, 200 mg រយៈពេល ៣យប់, ឬ 500 mg រយៈពេល ១យប់ប៉ុណ្ណោះ។

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅលិង្គ៖**

➡ លាបថ្នាំក្រែម 1% លើស្បែកដែលមានបញ្ហា រៀងរាល់យប់ រយៈពេល ៧យប់។

## Gentian violet (GV, methylrosanilinium chloride)

Gentian violet គឺជាថ្នាំសម្លាប់មេរោគ ប្រើដើម្បីប្រឆាំងនឹងការបង្ករោគនៅទ្វារមាស មាត់ និងស្បែក។

### សំខាន់ ⚠

Gentian violet ធ្វើឲ្យអ្វីៗជាប់ពណ៌ស្វាយ។ វារលុបពីស្បែកក្នុងរយៈពេលពីរបីថ្ងៃ ប៉ុន្តែអាចប្រឡាក់សម្លៀកបំពាក់ជាប់រហូត។

### របៀបប្រើ 

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស៖**

➡ ជ្រលក់សំឡីស្អាតក្នុងថ្នាំទឹក 1% រួចដាក់ក្នុងទ្វារមាសយ៉ាងជ្រៅរៀងរាល់យប់ រយៈពេល ៣យប់។ ត្រូវប្រាកដថាយកសំឡីចេញរៀងរាល់ព្រឹក។ ប្រសិនបើការបង្ករោគមិនចាប់ផ្ដើមធូរស្រាលក្នុងអំឡុងពេល ២ថ្ងៃទេ ចូរសាកល្បងអ្វីផ្សេងទៀត។

# Miconazole

Miconazole គឺជាថ្នាំប្រឆាំងនឹងមេរោគផ្សិត ប្រើសម្រាប់ព្យាបាលការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស លិង្គ និងស្បែក។

## ផលរំខាន 

Miconazole អាចធ្វើឲ្យរមាស់ស្បែក។ ឈប់ប្រើវាប្រសិនបើអ្នកឡើងកន្ទួល។

## របៀបប្រើ 

វាមានជាទម្រង់ថ្នាំសុលទ្វារមាស និងថ្នាំក្រែម។

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស៖**

➡ បើប្រើថ្នាំក្រែម 2% ៖ ដាក់ចំនួន 5 g ក្នុងទ្វារមាសរៀងរាល់យប់ រយៈពេល ៧យប់
ឬ
បើប្រើថ្នាំសុល៖ សុលមួយគ្រាប់យ៉ាងជ្រៅទៅក្នុងទ្វារមាសរៀងរាល់យប់ រួមទាំងពេលមករដូវ។
ប្រើថ្នាំសុល 100 mg រយៈពេល ៧យប់, ឬថ្នាំសុល 200 mg រយៈពេល ៣យប់។

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅលិង្គ៖**

➡ លាបថ្នាំក្រែម 2% លើស្បែកលិង្គត្រង់កន្លែងរងការប៉ះពាល់, ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ ទៅ ១៤ថ្ងៃ។

# Nystatin

Nystatin គឺជាថ្នាំប្រឆាំងមេរោគផ្សិត ប្រើសម្រាប់ព្យាបាលការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស លិង្គ មាត់ និងស្បែក។

## ផលរំខាន 

Nystatin អាចធ្វើឲ្យរមាស់ស្បែក។ ឈប់ប្រើវាប្រសិនបើអ្នកឡើងកន្ទួល។

## របៀបប្រើ 

វាមានជាទម្រង់ថ្នាំសុលទ្វារមាស និងថ្នាំក្រែម

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅទ្វារមាស៖**

➡ បើប្រើថ្នាំក្រែម៖ ដាក់ថ្នាំក្រែមទៅក្នុងទ្វារមាស មួយថ្ងៃពីរដង រយៈពេល ១០ ទៅ ១៤ថ្ងៃ
ឬ
បើប្រើថ្នាំសុល៖ ជ្រើមវាជាមុន រួចសុលថ្នាំ 100,000 IU ទៅក្នុងទ្វារមាសយ៉ាងជ្រៅ រៀងរាល់យប់ រយៈពេល ១៤យប់ រួមទាំងពេលមានរដូវ។

**សម្រាប់ការបង្ករោគដោយមេរោគផ្សិត នៅលិង្គ៖**

➡ លាបថ្នាំក្រែមលើស្បែកលិង្គដែលរងការប៉ះពាល់, ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ ទៅ ១៤ថ្ងៃ។

# ថ្នាំប្រឆាំងនឹងមេរោគ

## Acyclovir

Acyclovir គឺជាថ្នាំប្រើសម្រាប់ប្រឆាំងនឹងមេរោគនៃជំងឺពងបែកនៅប្រដាប់ភេទ។ Acyclovir មិនព្យាបាលជំងឺពងបែកនៅប្រដាប់ភេទ ឲ្យជាសះស្បើយទេ ប៉ុន្តែវាធ្វើឲ្យដំបៅមិនសូវឈឺចាប់ និងមិនឲ្យរាលដាល។

### ផលរំខាន

Acyclovir ជួនកាលអាចធ្វើឲ្យឈឺក្បាល វិលមុខ ចង្អោរ និងក្អួត។

### សំខាន់ ⚠

សូមកុំប្រើថ្នាំនេះ ប្រសិនបើអ្នកមានបញ្ហាតម្រងនោម។

### របៀបប្រើ

ចូរចាប់ផ្តើមប្រើថ្នាំ acyclovir ឲ្យបានឆាប់នៅពេលរោគសញ្ញាចាប់ផ្តើមចេញ។

**សម្រាប់ការឆ្លងជំងឺពងបែកលើប្រដាប់ភេទ លើកដំបូង៖**

➡ ផ្តល់ចំនួន 200 mg ជាថ្នាំលេប, ៥ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ
ឬ
ផ្តល់ចំនួន 400 mg ជាថ្នាំលេប, ៣ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ

**ប្រសិនបើអ្នកធ្លាប់មានជំងឺពងបែកនៅប្រដាប់ភេទ ពីមុនមក៖**

➡ ផ្តល់ចំនួន 200 mg ជាថ្នាំលេប, ៥ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ
ឬ
ផ្តល់ចំនួន 400 mg ជាថ្នាំលេប, ៣ដងក្នុងមួយថ្ងៃ រយៈពេល ៥ថ្ងៃ

ប្រសិនបើអ្នកមានចេញរោគសញ្ញា ៦ដងឬច្រើនជាងនេះក្នុងមួយឆ្នាំ ចូរជជែកជាមួយបុគ្គលិកសុខាភិបាលថា តើការប្រើថ្នាំ acyclovir រយៈពេលយូរ មានប្រយោជន៍ដែរឬទេ។

# ថ្នាំសម្រាប់ជំងឺសិរមាន់

## Podofilox

Podofilox មានជាទម្រង់ថ្នាំទឹក សម្រាប់ព្យាបាលសិរមាន់នៅជុំវិញប្រដាប់ភេទ និងទម្រង់ជាចាហួយសម្រាប់ព្យាបាលសិរមាន់នៅជុំវិញរន្ធគូថឬប្រដាប់ភេទ។ កុំច្រឡំវាជាមួយនឹងថ្នាំ podophyllin ដែលប្រើសម្រាប់ព្យាបាលជំងឺសិរមាន់ដែរ ប៉ុន្តែមានគ្រោះថ្នាក់ជាង ប្រសិនបើប្រើមិនត្រឹមត្រូវ។ Podofilox មានសុវត្ថិភាពជាង។

បុគ្គលិកសុខាភិបាលអាចលាបវាជាលើកដំបូងនៅក្នុងគ្លីនិក ដើម្បីបង្ហាញពីរបៀបប្រើវា។ អ្នកជំងឺប្រហែលជាត្រូវការជំនួយក្នុងការប្រើប្រាស់ថ្នាំ podofilox ប្រសិនបើសិរមាន់ពិបាកនឹងមើលឃើញ ឬដៃលាបមិនដល់។ លាបថ្នាំទឹកដោយប្រើដុំសំឡី ឬលាបចាហួយដោយប្រើម្រាមដៃ។ លាងសម្អាតដៃបន្ទាប់ពីប្រើប្រាស់។ រង់ចាំឲ្យថ្នាំស្ងួត មុននឹងស្លៀកពាក់វិញ។

### ផលរំខាន

Podofilox អាចធ្វើឲ្យរមាស់ស្បែក ធ្វើឲ្យស្បែកស្ពើង ប្រេះ និងហូរឈាម។

### សំខាន់ ⚠

សូមកុំប្រើថ្នាំនេះប្រសិនបើអ្នកមានផ្ទៃពោះ ឬបំបៅដោះកូន។

ប្រសិនបើរមាស់ស្បែកខ្លាំង ចូរកុំប្រើវាទៀត។

### របៀបប្រើ

**សម្រាប់ជំងឺសិរមាន់៖**

➡ ប្រើថ្នាំទឹក ឬថ្នាំចាហួយ លាបសិរមាន់ ពីរដងក្នុងមួយថ្ងៃ (ពេលព្រឹក និងពេលល្ងាច) រយៈពេល ៣ថ្ងៃ។ បន្ទាប់មកឈប់ប្រើចំនួន ៤ថ្ងៃ។ បន្តការព្យាបាល ៣ថ្ងៃ និងបញ្ឈប់ ៤ថ្ងៃ, ធ្វើបែបនេះរហូតដល់ ៤សប្តាហ៍សរុប។ ឈប់ប្រើថ្នាំនៅពេលសិរមាន់បាត់ទៅ។ ប្រសិនបើសិរមាន់ នៅតែមាន បន្ទាប់ពី ៤សប្តាហ៍ ចូរកុំបន្តប្រើថ្នាំ podofilix តទៅទៀត។ ជួបបុគ្គលិកសុខាភិបាលដើម្បីរកការព្យាបាលផ្សេងទៀត។

## Trichloroacetic acid និង bichloroacetic acid

Trichloroacetic acid ឬ bichloroacetic acid គឺជាជាតិអាស៊ីដដែលលាបពីលើសិរមាន់ ដើម្បីឲ្យវារួញ។ បុគ្គលិកសុខាភិបាលដែលមានបទពិសោធន៍ អាចលាបវាបានដោយមិនឲ្យរលាកធ្ងន់ធ្ងរ។

### ផលរំខាន

Trichloroacetic acid និង bichloracetic acid ធ្វើឲ្យស្បែកធម្មតាឈឺចាប់ឬខូច នៅពេលប៉ះនឹងស្បែក។

### សំខាន់ ⚠

ចូរប្រើដោយប្រុងប្រយ័ត្ន។ វានឹងរលាក ហើយអាចធ្វើឲ្យមានស្នាម។

### របៀបប្រើ

វាមានជាទម្រង់ថ្នាំទឹក ក្នុងកម្លាំង 10% ទៅ 35% ។

**សម្រាប់ជំងឺសិរមាន់៖**

➡ ជាដំបូង ចូរការពារតំបន់ជុំវិញសិរមាន់ ដោយប្រើចាហួយប្រេង។ បន្ទាប់មកប្រើដុំសំឡី ឬក្រណាត់ស្អាតបត់ឲ្យមានចុងស្រួច ដើម្បីលាប trichloroacetic acid ឬ bichloroacetic acid តែបន្តិចទៅលើសិរមាន់ម្តងបន្តិចៗរហូតទាល់តែវាប្រែពណ៌ជាស។ លាបក្នុងមួយសប្តាហ៍ម្តង រយៈពេល ១ ទៅ ៣សប្តាហ៍តាមការចាំបាច់។

វានឹងធ្វើឲ្យឈឺចាប់ប្រមាណ ១៥ ទៅ ៣០នាទី។ ប្រសិនបើវាប៉ះនឹងស្បែកធម្មតា ត្រូវលាងវាភ្លាមជាមួយទឹកនិងសាប៊ូ។

ប្រសិនបើការព្យាបាលមានប្រសិទ្ធភាព នោះនឹងមានដំបៅលេចឡើងត្រង់កន្លែងដែលធ្លាប់មានសិរមាន់។ បញ្ឈប់ការព្យាបាល។ បើមានការរលាកច្រើនពេក ត្រូវរង់ចាំយូរបន្តិច មុននឹងបន្តការព្យាបាលបន្ទាប់។ ដំបៅគួរសះក្នុងអំឡុង ១ ឬ ២សប្តាហ៍។ រក្សាភាពស្អាតនិងស្ងួតដល់ដំបៅ និងសង្កេតរកមើលការបង្ករោគ។

# ការរួមផ្សំថ្នាំដើម្បីព្យាបាលជំងឺប្រមេះទឹកបាយ និង ជំងឺប្រមេះទឹកថ្លា

ជំងឺប្រមេះទឹកបាយ និងជំងឺប្រមេះទឹកថ្លា ជាជំងឺកាមរោគ ២មុខដែលជាញឹកញាប់កើតឡើងក្នុងពេលតែមួយ ។ ត្រូវព្យាបាលដោយថ្នាំ ២ផ្សេងគ្នា។ សូមជ្រើសរើសថ្នាំ ១មុខពីផ្នែកខាងក្រោម។ សម្រាប់ផ្នែកនីមួយៗ ជម្រើសដ៏ល្អបំផុត ត្រូវបានសរសេរមុនគេ តាមលំដាប់លំដោយនៃជម្រើសល្អបន្ទាប់។ ឧទាហរណ៍ ការរួមផ្សំដ៏ល្អបំផុតគឺថ្នាំ ceftriaxone និង azithromycin ។

ម្យ៉ាងទៀត ត្រូវព្យាបាលដៃគូរបស់អ្នកជំងឺ ដោយថ្នាំដូចគ្នា។

| ថ្នាំពេទ្យ។ ប្រើថ្នាំមួយមុខ។ | ផ្ដល់ចំនួន | របៀបប្រើ |
|---|---|---|
| ceftriaxone | 250 mg | ចាក់ទៅក្នុងសាច់ដុំ, តែមួយដង ប៉ុណ្ណោះ |
| ឬ cefixime | 400 mg | ជាថ្នាំលេប, តែមួយដងប៉ុណ្ណោះ |
| ឬ spectinomycin | 2 grams (2000 mg) | ចាក់ទៅក្នុងសាច់ដុំ, តែមួយដង ប៉ុណ្ណោះ |
| **និង** | | |
| azithromycin | 1 gram (1000 mg) | ចាក់ទៅក្នុងសាច់ដុំ, តែមួយដង ប៉ុណ្ណោះ ជាថ្នាំលេប តែមួយដង ប៉ុណ្ណោះ |
| ឬ doxycycline (សូមកុំប្រើថ្នាំ doxycycline ប្រសិនបើអ្នកមានផ្ទៃពោះ និងចៀសវាងប្រើវា ប្រសិនបើអ្នកបំបៅដោះកូន) | 100 mg | ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ |
| ឬ erythromycin | 500 mg | ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ |
| ឬ tetracycline (សូមកុំប្រើថ្នាំ tetracycline បើអ្នកមានផ្ទៃពោះ ឬបំបៅដោះកូន) | 500 mg | ជាថ្នាំលេប, ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ |
| ឬ amoxicillin (អាចប្រើថ្នាំ amoxicillin បើអ្នកមានផ្ទៃពោះ ហើយគ្មានថ្នាំ azithromycin និង erythromycin) | 500 mg | ជាថ្នាំលេប, ៣ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ |

# ការរួមផ្សំថ្នាំដើម្បីព្យាបាលជំងឺរលាកត្រគាក

ជំងឺនេះជាទូទៅបង្កដោយមេរោគរួមផ្សំមួយចំនួន ដូច្នេះត្រូវការថ្នាំយ៉ាងតិច ២មុខ និងជួនកាល ៣មុខ ដើម្បីព្យាបាលឲ្យជាសះស្បើយ។ សូមជ្រើសរើសថ្នាំ ១មុខពីផ្នែកទាំង២ខាងក្រោម។ បើមាន សូមផ្តល់ថ្នាំ metronidazole ផងដែរ។ សម្រាប់ផ្នែកនីមួយៗ ជម្រើសដ៏ល្អបំផុត ត្រូវបានសរសេរមុនគេ តាមលំដាប់លំដោយនៃជម្រើសល្អបន្ទាប់។ ឧទាហរណ៍ ការរួមផ្សំដ៏ល្អបំផុតគឺថ្នាំ ceftriaxone និង doxycycline ។ បន្ទាប់ពី ៤៨ម៉ោង ប្រសិនបើថ្នាំមិនធ្វើឲ្យធូរស្រាលទេ ឬ រោគសញ្ញាមានធ្ងន់ធ្ងរ (មើលទំព័រ 11), ចូររកជំនួយពីគ្រូពេទ្យ។

ម្យ៉ាងទៀត ត្រូវព្យាបាលដៃគូរបស់អ្នកជំងឺចំពោះ ជំងឺប្រមេះទឹកបាយ និង ជំងឺប្រមេះទឹកថ្លា (មើលទំព័រ 42)។

| **ថ្នាំពេទ្យ។ ប្រើថ្នាំមួយមុខ។** | **ផ្តល់ចំនួន** | **របៀបប្រើ** |
|---|---|---|
| ceftriaxone | 250 mg | ចាក់ទៅក្នុងសាច់ដុំ, តែមួយដងប៉ុណ្ណោះ |
| ឬ spectinomycin | 2 grams (2000 mg) | ចាក់ទៅក្នុងសាច់ដុំ, តែមួយដងប៉ុណ្ណោះ |
| **និង** | | |
| **ថ្នាំពេទ្យ។ ប្រើថ្នាំមួយមុខ។** | **ផ្តល់ចំនួន** | **របៀបប្រើ** |
| doxycycline (សូមកុំប្រើថ្នាំ doxycycline បើអ្នកមានផ្ទៃពោះ ហើយចៀសវាងវាបើអ្នកកំពុងបំបៅដោះកូន) | 100 mg | ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ |
| ឬ azithromycin (លេបថ្នាំ azithromycin ជាមួយអាហារ, មានសុវត្ថិភាពក្នុងពេលមានផ្ទៃពោះ) | 1 gram (1000 mg) | ជាថ្នាំលេប តែមួយដូស, និងដូសទី២ នៅ១សប្តាហ៍បន្ទាប់ |
| ឬ erythromycin (មានសុវត្ថិភាពក្នុងពេលមានផ្ទៃពោះ) | 500 mg | ជាថ្នាំលេប ៤ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ |
| ឬ amoxicillin (អាចប្រើថ្នាំ amoxicillin បើអ្នកមានផ្ទៃពោះ ហើយគ្មានថ្នាំ azithromycin និង erythromycin) | 500 mg | ជាថ្នាំលេប ៣ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ |
| **និង** | | |
| **ថ្នាំពេទ្យសម្រាប់ជំងឺផ្សេងទៀត (ប្រើវា បើមាន)** | **ផ្តល់ចំនួន** | **របៀបប្រើ** |
| metronidazole | 400 ទៅ 500 mg | ជាថ្នាំលេប, ៣ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ |
| សំខាន់! សូមកុំផឹកស្រាក្នុងអំឡុងពេលលេបថ្នាំ metronidazole ។. | | |

# ការរួមផ្សំថ្នាំដើម្បីព្យាបាលទាំងជំងឺស្វាយ និង ជំងឺជំពៅប្រដាប់ភេទ

ពេលខ្លះយើងមិនអាចចែកដាច់រវាងជំងឺជំពៅប្រដាប់ភេទ និងជំងឺស្វាយទេ។ ប្រសិនបើអ្នកមិនច្បាស់ថាគាត់មានជំងឺណាមួយ ឬមានទាំងពីរ ល្អបំផុតគឺព្យាបាលទាំងពីរក្នុងពេលតែមួយ។ ជ្រើសរើសថ្នាំ ១មុខពីប្រអប់នីមួយៗ។ សម្រាប់ផ្នែកនីមួយៗ ជម្រើសដ៏ល្អបំផុត ត្រូវបានសរសេរមុនគេ តាមលំដាប់លំដោយនៃជម្រើសល្អបន្ទាប់។ ឧទាហរណ៍ ការរួមផ្សំដ៏ល្អបំផុតគឺថ្នាំ benzathine penicillin និងថ្នាំ azithromycin ។ ប្រសិនបើអ្នកប្រើថ្នាំ erythromycin ដើម្បីព្យាបាលជំងឺស្វាយ, សូមកុំប្រើថ្នាំ azithromycin ឬថ្នាំ erythromycin សម្រាប់ព្យាបាលជំងឺជំពៅប្រដាប់ភេទ។

| **ថ្នាំសម្រាប់ព្យាបាលជំងឺស្វាយ។ ប្រើថ្នាំមួយមុខ។** | **ផ្ដល់ចំនួន** | **របៀបប្រើ** |
|---|---|---|
| benzathine penicillin (អាចប្រើប្រសិនបើមានផ្ទៃពោះ) | 2.4 million Units | ចាក់ទៅក្នុងសាច់ដុំ, តែម្ដងប៉ុណ្ណោះ |
| ឬ doxycycline (សូមកុំប្រើថ្នាំ doxycycline បើអ្នកមានផ្ទៃពោះនិងចៀសវាងប្រើបើអ្នកបំបៅដោះកូន) | 100 mg | ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ១៤ថ្ងៃ |
| ឬ erythromycin (ប្រើថ្នាំនេះលុះត្រាតែអ្នកមានផ្ទៃពោះ ឬបំបៅដោះកូន ហើយអាល់ឡែស៊ីនឹងថ្នាំ penicillin ប៉ុណ្ណោះ។ វានឹងព្យាបាលជំងឺស្វាយចំពោះម្ដាយ ប៉ុន្តែបន្ទាប់ពីកើតទារកនឹងត្រូវការការព្យាបាលបន្ថែម) | 500 mg | ជាថ្នាំលេប ៤ដងក្នុងមួយថ្ងៃ រយៈពេល ១៥ថ្ងៃ |
| **និង** | | |
| **ថ្នាំសម្រាប់ព្យាបាលជំងឺជំពៅប្រដាប់ភេទ។ ប្រើថ្នាំ ១មុខ។** | **ផ្ដល់ចំនួន** | **របៀបប្រើ** |
| azithromycin | 1 gram (1000 mg) | ជាថ្នាំលេប, តែម្ដងប៉ុណ្ណោះ |
| ឬ ceftriaxone | 250 mg | ចាក់ទៅក្នុងសាច់ដុំ, តែម្ដងប៉ុណ្ណោះ |
| ឬ ciprofloxacin (សូមកុំប្រើបើមានផ្ទៃពោះ ឬបំបៅដោះកូន ឬអាយុក្រោម ១៦ឆ្នាំ) | 500 mg | ជាថ្នាំលេប, ២ដងក្នុងមួយថ្ងៃ រយៈពេល ៣ថ្ងៃ |
| ឬ erythromycin | 500 mg | ជាថ្នាំលេប ៤ដងក្នុងមួយថ្ងៃ រយៈពេល ៧ថ្ងៃ |